អនុម័តក្នុងកិច្ចប្រជុំAMAF លើកទី ៣៩
ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០១៧

# ក្របខ័ណ្ឌដៃគូរសហការជាសាធារណៈនិងឯកជនក្នុងសមាគមអាស៊ានសម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យានៅក្នុងវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (FAF)

## 2017

Translated from the ASEAN Public-Private Partnership Regional Framework for Technology Development in the Food, Agriculture and Forestry (FAF) Sector

Disclaimer: This is an unofficial translation and provided for reference only.

ASEAN Public-Private Partnership Regional Framework for Technology Development in the Food, Agriculture and Forestry (FAF) Sector, 2017

To find the original version of the guideline please visit the ASEAN Secretariat website, https://asean.org/ or download at https://asean-crn.org/relevant-asean-guidelines-on-land-use/.

The translation has been produced with the support of the Climate Smart Land Use in ASEAN (CSLU) project, funded by the German Ministry for Economic Cooperation and Development and implemented by the Deutsche Gesellschaft für Internationale Zusammenarbeit (GIZ).

german cooperation
DEUTSCHE ZUSAMMENARBEIT

implemented by:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

In cooperation with
asean

# Table of Contents


បញ្ជីនៃពាក្យកាត់ .......... 4

សទ្ទានុក្រមពាក្យ .......... 5

1. សារតា .......... 6

2. វត្ថុបំណង .......... 6

3. និយមន័យនិងវិសាលភាពរបស់ PPP .......... 7

4. ភាពជាដៃគូសាធារណៈនិងឯកជន ក្នុងក្របខ័ណ្ឌតំបន់អាស៊ាន .......... 9

4.1 គោលនយោបាយនិងក្របខ័ណ្ឌច្បាប់របស់ភាពជាដៃគូសាធារណៈនិងឯកជន នៅក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម និងព្រៃឈើ .......... 9

4.2 ក្របខ័ណ្ឌស្ថាប័នជាមួយនិងតួនាទីនិងការទទួលខុសត្រូវ .......... 11

4.3 ការអភិវឌ្ឍន៍ និងការអនុវត្ត ភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) .......... 12

4.4 តំបន់នៃកិច្ចសហប្រតិបត្តិការ .......... 14

4.5 នីតិវិធីសម្រាប់ការអភិវឌ្ឍគម្រោងនិងការអនុវត្ត .......... 15

5. កត្តាជម្រុញនិងស្ថិរភាពនៃភាពជាដៃគូសាធារណៈ-ឯកជន .......... 18

5.1 ដំណាក់កាលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍និងការធ្វើពាណិជ្ជកម្មតាមខ្សែ សង្វាក់តម្លៃ .......... 18

5.2. អ្នកបើកបរនៃភាពជាដៃគូជាមួយវិស័យឯកជន .......... 18

6. ផែនការសកម្មភាពដើម្បីលើកកម្ពស់ការអនុវត្តគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) .......... 20

6.1 ការយល់ដឹងអំពី ភាពជាដៃគូសាធារណៈនិងឯកជន (PPP) និងការកំណត់អត្តសញ្ញាណឱកាស .......... 20

6.2 ការកសាងសមត្ថភាពនិងឧបករណ៍ត្រៀមខ្លួនសម្រាប់គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) .......... 22

6.3 ការសន្ទនាឯកជននិងសាធារណៈនិងវេទិកាភាពជាដៃគូសាធារណៈនិងឯកជន (PPP) .......... 23

7. ការអនុវត្តនិងការគ្រប់គ្រង .......... 24

# បញ្ជីនៃពាក្យកាត់

| | |
|---|---|
| AMS | រដ្ឋសមាជិកអាស៊ាន (ASEAN Member States) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of Southeast Asian Nations) |
| ASOF | មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ (ASEAN Senior Officials on Forestry) |
| ASWGC | ក្រុមការងារតំបន់អាស៊ានស្តីពីដំណាំ (ASEAN Sectoral Working Group on Crops) |
| ASWGFi | ក្រុមការងារតំបន់អាស៊ានស្តីពីជលផល (ASEAN Sectoral Working Group on Fisheries) |
| ASWGL | ក្រុមការងារតំបន់អាស៊ានស្តីពីបសុសត្វ (ASEAN Sectoral Working Group on Livestock) |
| ATWGARD | ក្រុមការងារបច្ចេកទេសអាស៊ានស្រាវជ្រាវនិង អភិវឌ្ឍន៍ស្តីពីវិស័យកសិកម្ម (ASEAN Technical Working Group on Agricultural R&D) |
| CGIAR | ក្រុមពិគ្រោះយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ (Consultative Group on International Agricultural Research) |
| CSA | កសិកម្មអាកាសធាតុឆ្លាតវៃ (Climate Smart Agriculture) |
| CSO | អង្គការសង្គមស៊ីវិល (Civil Society Organisation) |
| CSR | ទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន (Corporate Social Responsibility) |
| EIU | អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (Economist Intelligence Unit) |
| ERIA | វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា (Economic Research Institute for ASEAN and East Asia) |
| ESCAP | គណ:កម្មការសេដ្ឋកិច្ចនិងសង្គមសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (Economic and Social Commission for Asia and the Pacific) |
| FAF | ស្បៀងអាហារកសិកម្មនិងព្រៃឈើ (Food, Agriculture, and Forestry) |
| FO | អង្គការកសិករ (Farmers' Organisation) |
| NARS | ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (National Agricultural Research System) |
| M&E | ការតាមដាននិងវាយតម្លៃ (Monitoring and Evaluation) |
| MSMEs | សហគ្រាសខ្នាតតូចនិងមធ្យម (Micro, Small and Medium Enterprises) |
| PPP | ភាពជាដៃគូសាធារណ:និងឯកជន (Public-Private Partnership) |
| R&D | ការស្រាវជ្រាវនិងអភិវឌ្ឍន៍ (Research and Development) |
| S&T | វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (Science and Technology) |
| SEARCA | មជ្ឈមណ្ឌលប្រចាំតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការសិក្សាជាន់ខ្ពស់និងស្រាវជ្រាវក្នុងវិស័យកសិកម្ម (Southeast Asian Regional Centre for Graduate Studies and Research in Agriculture) |
| SOM-AMAF | កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ - រដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ានSenior (Officials Meeting – ASEAN Ministers of Agriculture and Forestry) |
| SPS | អនាម័យនិងភូតគាមចំណីអាហារ (Sanitary and Phytosanitary) |
| TDFAF | ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (Technology Development for Food, Agriculture, and Forestry) |

# សទ្ទានុក្រមពាក្យ

**ការវិភាគថ្លៃដើមផលិតកម្ម៖**
វិធីសាស្ត្រជាប្រព័ន្ធសម្រាប់ប៉ាន់ប្រមាណនិងប្រៀបធៀបអត្ថប្រយោជន៍និងថ្លៃដើម របស់គម្រោង។

**ភាពជាដៃគូពាណិជ្ជកម្ម៖**: ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលមាន ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ និងក្រសួងផ្សេងៗធ្វើការផ្ទេរការសិក្សានិង លទ្ធផលស្រាវជ្រាវ និងសម្ភារៈទៅឱ្យក្រុមហ៊ុនឯកជនសម្រាប់ធ្វើពាណិជ្ជកម្ម ទីផ្សារ និងការចែកចាយ។

**ភាពជាដៃគូកិច្ចសន្យា៖** ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលមាន ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ និងក្រសួងផ្សេងៗធ្វើការសហការជាមួយសហគ្រាសឯកជនដែលមានមធ្យោបាយឬជំនាញដើម្បីធ្វើការស្រាវជ្រាវលើផ្នែកខ្លះ។

**ភាពជាដៃគូស្រាវជ្រាវចំណេះដឹងមូលដ្ឋាន៖** ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលមានប្រព័ន្ធស្រាវជ្រាវ កសិកម្មជាតិ និងក្រសួងផ្សេងៗរួមជាមួយសហគ្រាសឯកជនរួមគ្នាអនុវត្ត សកម្មភាពស្រាវជ្រាវកម្រិតកំពូល។

**ផ្លូវនៃផលប៉ះពាល់៖** ការពិពណ៌នាលំអិតអំពីសកម្មភាព និងការរំពឹងទុកអំពីទំនាក់ទំនង ទូទៅរវាងលទ្ធផលដែលចង់បាន លទ្ធផលដែលទទួលបាន និងផលប៉ះពាល់។

**ការកំណត់អាទិភាព៖** នៅក្នុងការស្រាវជ្រាវ ដំណើរការនៃការកំណត់អត្តសញ្ញាណ ជម្រើសសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍន៍ និងការកំណត់អាទិភាពលើជម្រើស ទាំងនេះដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ជាមុននិងត្រូវធ្វើឡើង តាមវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ។

**ភាពជាដៃគូឯកជននិងសាធារណៈ៖** ជាកិច្ចព្រមព្រៀងកិច្ចសន្យារវាងរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនដែលមានគោលដៅឆ្ពោះទៅរកការផ្តល់ហិរញ្ញប្បទាន ការរចនា ការអនុវត្តនិងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាកម្មដែលធ្លាប់ ជាទំនួលខុសត្រូវរបស់វិស័យសាធារណៈ។

**ទំនិញសាធារណៈ៖** ជាផលិតផលឬសេវាកម្មដែលផ្តល់ដោយមិនមានផល ចំណេញដល់ប្រជាជនទូទៅវាអាចត្រូវបានផ្តល់ឱ្យដោយរដ្ឋាភិបាល ឬបុគ្គលឯកជន ឬអង្គការ។

**ភាពជាដៃគូធនធាន៖** ភាពជាដៃគូសាធារណៈនិងឯកជន(PPP) ដែលមាន ប្រព័ន្ធ ស្រាវជ្រាវកសិកម្មជាតិ និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទធ្វើការ សហការជាមួយមូលនិធិ សប្បុរសធម៌ដែលធ្វើការទាក់ទងជាមួយ សហគ្រាសឯកជន ដើម្បីទទួលបានជំនួយ ឬទទួលបានជំនាញវិទ្យាសាស្ត្រពី សហគ្រាសឯកជនទាំងនោះ។

**ភាពជាដៃគូអភិវឌ្ឍន៍តាមវិស័យឬ ខ្សែសង្វាក់តម្លៃ៖** ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលស្ថិនៅក្នុង ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ និងក្រសួងផ្សេងៗទៀតសហការក្នុងភាពជាដៃគូរវាង វិស័យសាធារណៈ ជនឯកជន និងសង្គមស៊ីវិល និងសហគមន៍អ្នកស្រាវជ្រាវ និងវិទ្យាសាស្ត្រ ដោយធ្វើការរួមគ្នាដើម្បីចូលរួមអភិវឌ្ឍន៍លើអនុវិស័យទំនិញឬ ខ្សែសង្វាក់តម្លៃដែលពាក់ព័ន្ធផ្សេងៗ។

**ទ្រឹស្តីនៃការផ្លាស់ប្តូរ៖**
គឺជាសេចក្តីពិពណ៌នានិងការបង្ហាញដ៏លំអិតមួយអំពីរបៀបនិងមូលហេតុដែលធ្វើឱ្យមានការចង់បានការផ្លាស់ប្តូរនៅក្នុងបរិបទជាក់លាក់មួយ។

**ការវិភាគតម្លៃសម្រាប់ប្រាក់៖**
គឺជាវិធីសាស្ត្រមានលក្ខណៈជាប្រព័ន្ធសម្រាប់ការធ្វើចំណាត់ថ្នាក់ជម្រើសដែលមាន ដោយផ្អែកលើលក្ខណ្ឌនៃការទទួលបានអត្ថប្រយោជន៍ខ្ពស់បំផុតសម្រាប់ការចំណាយថ្លៃដើមណាមួយ ឬការចំណាយថ្លៃដើមដែលទាបបំផុតដើម្បីទទួលបានអត្ថប្រយោជន៍ដែលបានត្រូវផ្តល់ជូនណាមួយ។វាក៏ត្រូវបានគេស្គាល់ផងដែរថាជា ការវិភាគប្រសិទ្ធភាពនៃការចំណាយ។

**កម្មវិធីជំរុញលទ្ធផលសម្រាប់ប្រាក់ដែលបានចំណាយ៖** គឺជាកត្តាមួយដែលពន្យល់ អំពីមូលហេតុដែលជម្រើសជាក់លាក់មួយ (ឧទាហរណ៍ការអនុវត្តដោយអង្គភាពឯកជន) នឹងទទួលបានលទ្ធផលសម្រាប់ប្រាក់ដែលបានចំណាយ ល្អជាងជម្រើសដែល ជាលំនាំដើម (ឧទាហរណ៍ការអនុវត្តដោយអង្គភាពសាធារណៈ) ។

## 1. សាវតា

កិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ានក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) កំណត់ចក្ខុវិស័យនិងផែនការយុទ្ធសាស្ត្រសម្រាប់ វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ២០១៦-២០២៥ ជាវិស័យដែលប្រកួតប្រជែង មានភាពបរិយាប័ន្ន ភាពធន់ និងនិរន្តរភាព ដែលរួមបញ្ចូលជាមួយសេដ្ឋ កិច្ចពិភពលោក ដោយផ្អែកលើទីផ្សារតែមួយ និង មូលដ្ឋានផលិតកម្មដែលរួមចំណែក ដល់សន្តិសុខស្បៀង អាហារូបត្ថម្ភនិងវិបុលភាពនៅក្នុងសហគមន៍អាស៊ាន” ។ ចំណុចដែលសំខាន់ជាងគេដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យមួយនេះ គឺការបង្កើនផលិតភាពប្រកបដោយនិរន្តរភាព និងការកាត់បន្ថយការបាត់បង់មុននិងក្រោយនៃការប្រមូលផលតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា “បៃតង” ហើយនិង ប្រព័ន្ធគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព។ ការអនុវត្តកសិកម្មឆ្លាតវៃអាកាសធាតុ (CSA) ដែលរួមមាន (១) ការរួមបញ្ចូលនូវការបង្កើនផលិតភាពនិងសន្តិសុខស្បៀង (២) ភាពធន់នឹងការប្រែប្រួលអាកាសធាតុនិង (៣) ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលគឺជាធាតុផ្សំសំខាន់មួយនៃប្រព័ន្ធគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពនៅក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF)។ការច្នៃប្រឌិតនិងចំណេះដឹងគឺជាកត្តាសំខាន់ក្នុងការជំរុញការប្រកួតប្រជែងប្រកបដោយនិរន្តរភាព។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍បច្ចេកវិទ្យាតែមួយឯងក៏មិនគ្រប់គ្រាន់ដែរ។ អ្វីដែលសំខាន់គឺជាការធ្វើពាណិជ្ជកម្ម និងការចែកចាយបច្ចេកវិទ្យាដែលចាំបាច់ សម្រាប់ការផ្តល់ដំណោះស្រាយរួម និងធានាថាដំណោះស្រាយទាំងនេះត្រូវបានពង្រីកប្រកបដោយនិរន្តរភាពនិង បរិយាប័ន្ន។ ការបង្កើតភាពជាដៃគូជាមួយវិស័យឯកជននៅទូទាំងសង្វាក់តម្លៃក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) គឺមានភាពចាំបាច់ណាស់សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យា និងការចែកចាយនៅក្នុងវិស័យនេះ។ ភាពជាដៃគូជាមួយវិស័យឯកជនក៏មានសារៈសំខាន់ផងដែរក្នុងការបង្កើនការវិនិយោគទៅក្នុងការបង្កើតអ្វីដែលថ្មី ដែលជាអ្វីមួយដែលវិស័យសាធារណៈមិនអាចធ្វើតែឯងបាន។

ក្នុងន័យនេះសមាគមអាស៊ានបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការជម្រុញឱ្យមានការវិនិយោគពីសំណាក់វិស័យឯកជនក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យានៅក្នុងវិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) តាមរយៈភាពជាដៃគូឯកជននិងសាធារណៈ (PPP) ក៏ដូចជាកិច្ចសហការរវាងរដ្ឋដែលជាសមាជិកអាស៊ាន (AMS) វិទ្យាស្ថានស្រាវជ្រាវអន្តរជាតិ និងដៃគូអភិវឌ្ឍន៍។

នៅក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) គឺជាយន្តការដ៏សំខាន់មួយដែលសមាគមអាស៊ានព្យាយាមលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យា ធនធាន ជំនាញ និងការចូលទៅកាន់ទីផ្សារដើម្បីលើកកម្ពស់ផលិតភាព និងការប្រកួតប្រជែងក្នុងវិស័យកសិកម្មក៏ដូចជាធានាឱ្យបាននូវនិរន្តរភាពនិងបរិយាប័ន្ន។

## 2. វត្ថុបំណង

វត្ថុបំណងរួមនៃក្របខ័ណ្ឌភាពជាដៃគូសាធារណៈនិងឯកជនក្នុងតំបន់អាស៊ានសម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាក្នុងវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) គឺដើម្បីបង្កើនការវិនិយោគរួមគ្នាក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យាប្រកបដោយនិរន្តរភាពការអនុម័ត និងការផ្សព្វផ្សាយនៅទូទាំងសង្វាក់តម្លៃទាំងមូលនៅក្នុងវិស័យ ចំណីអាហារ កសិកម្ម និងព្រៃឈើ នៅអាស៊ាន។

ក្របខ័ណ្ឌភាពជាដៃគូសាធារណៈនិងឯកជនក្នុងតំបន់អាស៊ានសម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាក្នុងវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) ត្រូវបានគេរំពឹងថានឹងរួមចំណែកដល់កម្មវិធីសកម្មភាពដូចខាងក្រោមដែលស្ថិតនៅក្រោមផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកស្បៀងអាហារ កសិកម្ម និងព្រៃឈើ ឆ្នាំ ២០១៦-២០២៥ - យុទ្ធសាស្ត្រទី ១៖

(1) បង្កើនការចូលរួមរបស់វិស័យឯកជនក្នុងការពិភាក្សាគោលនយោបាយកម្មវិធីនិងការបង្កើតគម្រោង ការស្រាវជ្រាវនិងការអភិវឌ្ឍន៍ ព្រមទាំងផ្តល់ការលើកទឹកចិត្ត និងជំរុញ និងបង្កើតបរិយាកាសល្អប្រសើរសម្រាប់ឱ្យភាពជាដៃគូរវាងរដ្ឋនិងឯកជនឆ្ពោះទៅរកការបង្កើន ផលិតភាពនិងគុណភាព។

(2) បង្កើនការវិនិយោគក្នុងសកម្មភាពសហការស្រាវជ្រាវនិងអភិវឌ្ឍន៍និងពង្រឹងកិច្ចសហការក្នុងតំបន់ដែលមានស្រាប់ក្នុងចំណោមប្រទេសដែលជាសមាជិក និងជាមួយអង្គការអន្តរជាតិសំខាន់ៗដើម្បីអភិវអភិវឌ្ឍន៍បច្ចេកវិទ្យា

ប្រកបដោយនិរន្តរភាព និងប្រព័ន្ធគ្រប់គ្រង និងការប្រមូលផលហើយនិងការពង្រីកប្រព័ន្ធទំនាក់ទំនង និងចែកចាយបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព។

(3) ផ្តល់ជាយន្តការស្ថាប័ននិងការលើកទឹកចិត្តសមស្របសម្រាប់ភាពជាដៃគូសាធារណៈនិងឯកជនក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការចែករំលែកបច្ចេកវិទ្យាតាមរយៈការសហការជាមួយវិស័យឯកជនដើម្បីកំណត់ចំណុចស្រាវជ្រាវដែលជាអាទិភាពជាមួយនឹងទទួលបាននូវប្រាក់ចំណេញឯកជននិងសុខុមាលភាពសង្គមហើយប្រើវាជាចំណុចសម្រាប់ការបង្កើតនិងចែករំលែកបច្ចេកវិទ្យា។

(4) ធ្វើការត្រួតពិនិត្យឡើងវិញឱ្យបានទៀងទាត់នូវលក្ខណៈនៃភាពជាដៃគូក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍និងភាពជាដៃគូយុទ្ធសាស្ត្រជាមួយអង្គការពាក់ព័ន្ធដើម្បីធានាឱ្យបានថារបៀបវារៈនៃការស្រាវជ្រាវនិងបណ្តុះបណ្តាលមានភាពសមស្របគ្នាទៅនឹងគោលដៅសមាគមអាស៊ាន។

(5) កំណត់អត្តសញ្ញាណនិងចងក្រងឯកសារអំពីប្រវត្តិនៃភាពជោគជ័យរបស់បច្ចេកវិទ្យានិងស្វែងយល់ពីវិធីសាស្ត្រថ្មីៗនៃការបង្កើនវិសាលភាពដែលរួមមានការពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍និងមធ្យោបាយទំនាក់ទំនងផ្សេងៗទៀតសម្រាប់ការផ្សព្វផ្សាយនិងចែកចាយនូវបច្ចេកវិទ្យានិងប្រព័ន្ធគ្រប់គ្រងដែលជោគជ័យនៅទូទាំងប្រទេសសមាជិកអាស៊ាន។

(6) ធ្វើឱ្យមានស្តង់ដារនិងសុខដុមនីយកម្មនូវវិធីសាស្ត្រ និងការបង្ហាញស្ថិតិជាតិនិងពង្រឹងសមត្ថភាពបច្ចេកទេសរបស់ប្រទេសជាសមាជិកដើម្បីនាំឱ្យមានការសិក្សាស្រាវជ្រាវពហុប្រទេសនិងអនុវត្តការវិភាគនិងរៀបចំផែនការស្ថានភាពបានត្រឹមត្រូវ។

ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន
គោលបំណងនៃក្របខ័ណ្ឌភាពជាដៃគូសាធារណៈនិងឯកជនសម្រាប់
ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម និងព្រៃឈើគឺដើម្បី
ផ្តល់ការណែនាំដល់ប្រទេសជាសមាជិកអាស៊ានអំពីរបៀបបង្កើតបរិយាកាសភាពជាដៃគូសាធារណៈនិងឯកជនដែលមានភាពអាចព្យាករណ៍បាន
និងមានប្រសិទ្ធភាពសម្រាប់ការលើកកម្ពស់ការអភិវឌ្ឍន៍បច្ចេកវិទ្យានិងការផ្សព្វផ្សាយនៅក្នុងខ្សែសង្វាក់តម្លៃរបស់ វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ។
វាក៏មានគោលបំណងក្នុងការរួមចំណែកបង្កើនការធ្វើសុខដុមនីយកម្មនៃគោលនយោបាយ
ភាពជាដៃគូសាធារណៈនិងឯកជន ក្របខ័ណ្ឌច្បាប់
និងការរៀបចំស្ថាប័ននៅក្នុងប្រទេសជាសមាជិកអាស៊ាន។ ក្របខ័ណ្ឌ ភាពជាដៃគូសាធារណៈនិងឯកជនសម្រាប់ ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម
និងព្រៃឈើនឹងដើរតួជាឯកសារយោងដើម្បីបង្ហាញអំពីការប្តេជ្ញាចិត្តផ្នែកនយោបាយរបស់ប្រទេសជាសមាជិកក្នុងការលើកកម្ពស់ ភាពជាដៃគូសាធារណៈនិងឯកជន។ លើសពីនេះទៀត
វាជាយុទ្ធសាស្ត្រដើម្បីទាក់ទាញការចាប់អារម្មណ៍ឱ្យកាន់តែខ្លាំងនិងមានភាពស្របគ្នាពីវិស័យឯកជនក្នុងការចូលរួម។

## 3. និយមន័យនិងវិសាលភាពរបស់ PPP

និយមន័យរបស់ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលអាចស្វែងរកបាននៅក្នុងបណ្តាឯកសារផ្សេងៗ គឺមានលក្ខណៈតូចចង្អៀតដែលផ្តោតសង្កត់តែទៅលើហេដ្ឋារចនាសម្ព័ន្ធតែប៉ុណ្ណោះ។ ជាឧទាហរណ៍ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា (ERIA) បានកំណត់និយមន័យរបស់ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ថាជាវិធីសាស្ត្រលទ្ធកម្មឯកទេសដែល ត្រូវបានផ្តល់ដោយរដ្ឋាភិបាល សម្រាប់ទទួលខុសត្រូវលើទំនិញសាធារណៈ និងសេវាកម្មហេដ្ឋារចនាសម្ព័ន្ធ។ ដូចគ្នានេះផងដែរធនាគារពិភពលោកបានកំណត់និយមន័យរបស់ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ថាជាការរៀបចំកិច្ចសន្យារវាងអង្គភាពសាធារណៈឬអាជ្ញាធរមានសមត្ថកិច្ចជាមួយនិងអង្គភាពឯកជនសម្រាប់ការផ្តល់ទ្រព្យសម្បត្តិឬសេវាកម្មសាធារណៈដែលភាគីឯកជននឹងទទួលខុសត្រូវលើហានិភ័យដែលមាននិងការទទួលខុសត្រូវលើផ្នែកគ្រប់គ្រង។

អាចត្រូវបានផ្តល់និយមន័យឱ្យកាន់តែទូលំទូលាយថាជាកិច្ចកិច្ចសន្យាព្រមព្រៀងគ្នារវាងរដ្ឋាភិបាលនិងក្រុមហ៊ុនឯកជនដែលមានគោលដៅឆ្ពោះទៅកាន់ការផ្តល់ហិរញ្ញប្បទាន ការរចនា ការអនុវត្ត និងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ គ្រឿងបរិក្ខារនិង សេវាកម្ម ដែល ធ្លាប់បានផ្តល់និងគ្រប់គ្រងដោយវិស័យសាធារណៈ។ ដោយសារតែមានបញ្ហា ប្រឈមជាមួយនិង វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ភាពជាដៃគូគួរតែគ្របដណ្តប់លើការអភិវឌ្ឍន៍ ការអនុម័ត និងការផ្សព្វផ្សាយបច្ចេកវិទ្យាប្រកបដោយនិរន្តរភាពដែលឆ្ពោះទៅរក ការពង្រឹងសន្តិសុខស្បៀងអាហារ និងភាពធន់ជាមួយនឹងអាកាសធាតុ។ ឧទាហរណ៍ ដូចជាការកែច្នៃប្រឌិតដើម្បីសន្សំសំចៃការប្រើប្រាស់ទឹក

កសិកម្មអភិរក្ស និងប្រព័ន្ធ ផ្សេងៗដែលស្រដៀងគ្នាផងដែរ។

ក្រុមពិគ្រោះយោបល់នៃអង្គការការស្រាវជ្រាវកសិកម្មអន្តរជាតិ (CGIAR)បានបែងចែក ប្រភេទទម្រង់នៃ PPP ដូចខាងក្រោម៖ ភាពជាដៃគូធនធាន ភាពជាដៃគូរកិច្ចសន្យា ភាពជាដៃគូក្នុងការស្រាវជ្រាវចំណេះដឹងបឋម ភាពជាដៃគូពាណិជ្ជកម្ម និងភាពជាដៃគូអភិវឌ្ឍន៍ខ្សែសង្វាក់វិស័យនិងតម្លៃ ដែលមានលក្ខណៈសម្បត្តិដូច ខាងក្រោម:

**ក្នុងភាពជាដៃគូធនធាន** វិស័យឯកជនចូលរួមចំណែកហិរញ្ញវត្ថុ ឬធនធានមនុស្សដល់ គម្រោងស្រាវជ្រាវ ឬកម្មវិធីរបស់ស្ថាប័នសាធារណៈ។ នៅពេលដែលវិស័យឯកជន ផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវដល់ទីភ្នាក់ងារសាធារណៈ ប្រភពមូលនិធិ ដ៏សំខាន់គឺនៅតែជាមូលនិធិសប្បុរសធម៌ (ទោះបីជាក្រុមហ៊ុនឯកជនខ្លះផ្តល់ វិភាគទានដោយផ្ទាល់ដោយមិនឆ្លងកាត់អង្គការមិនរកប្រាក់ចំណេញក៏ដោយ) ។

**ភាពជាដៃគូក្នុងកិច្ចសន្យា**គឺជាការរៀបចំជួលធនធានខាងក្រៅដើម្បីបំពេញកិច្ចការដែលធ្លាប់ជាផ្នែកមួយ នៅក្នុងលទ្ធកម្មសាធារណៈ។ ទោះយ៉ាងណាក៏ដោយ ដោយសារតែការស្រាវជ្រាវនិងការអភិវឌ្ឍន៍កសិកម្មសាធារណៈ តែងតែត្រូវបានធ្វើនៅតាមផ្ទះ ការផ្គត់ផ្គង់មកពីខាងក្រៅត្រូវបានគេចាត់ទុកថាជារបៀបផ្តល់ជូនដែលមិនមែនជាប្រពៃណីហើយដូច្នេះវា ជាឧទាហរណ៍មួយរបស់របស់ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ។ ភាពជាដៃគូកិច្ចសន្យា អាចមានការពាក់ព័ន្ធជាមួយនឹងពាក្យបច្ចេកទេសដែលទាក់ទងជាមួយកិច្ចសហការលើសេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធដូចជា៖

- វិស័យសាធារណៈជាម្ចាស់នៃគ្រឿងបរិក្ខារ ខណៈដែលវិស័យឯកជនផ្តល់នូវ អ្នកស្រាវជ្រាវនិងការចូលរួមផ្សេងទៀតដូចជា ចំណេះដឹង (ឧទាហរណ៍ រោគសាស្ត្រជាក់លាក់ និងពិធីការព្យាបាលក្នុងករណីរុក្ខជាតិឬសត្វមានជំងឺ) ឬផលិតផលដែលមានប៉ាតង់ (ឧទាហរណ៍ការកែលម្អគ្រាប់ពូជ) ។ ទម្រង់នៃភាពជាដៃគូនេះអាចពាក់ព័ន្ធនឹងការកសាងសមត្ថភាពសម្រាប់ដៃគូ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS)។
- ដៃគូរប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS) ផ្តល់ជូននូវអ្នកស្រាវជ្រាវ អគារ និងការិយាល័យ ខណៈដៃគូឯកជនវិនិយោគលើឧបករណ៍ពិសោធន៍ធន់ធ្ងន់ៗ សម្រាប់តែការប្រើប្រាស់ក្នុងគម្រោងប៉ុណ្ណោះ។ ចំពោះឧបករណ៍ដែល នៅសល់និងត្រូវបានរក្សាទុកជាមួយដៃគូ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS) (ចំណុចនេះជាប្រភេទមួយនៃគម្រោង បង្កើត-ប្រតិបត្តិការ-ផ្ទេរ ហេដ្ឋារចនាសម្ព័ន្ធរបស់ ភាពជាដៃគូសាធារណៈនិងឯកជន) ។ វិស័យឯកជន ក៏អាច ផ្តល់ជូននូវចំណេះដឹងនិងសកម្មភាពពាក់ព័ន្ធនឹងការកសាង សមត្ថភាពផងដែរ។
- ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS) ឬដៃគូឯកជនត្រូវបានចុះកិច្ចសន្យា ក្នុងការផ្តល់ជូននូវសេវាកម្មដែលមានកម្រិតបច្ចេកទេសខ្ពស់ហើយនិងជាជំនាញដែល តែងតែជាតម្រូវការម្តងហើយម្តងទៀតដូចជាការចាប់សញ្ញាពីចម្ងាយ ការធ្វើផែនទីម៉ូលេគុល ។ល។

**ភាពជាដៃគូក្នុងការស្រាវជ្រាវចំណេះដឹងបឋម**
ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍អ្នកដែលមានសមត្ថភាពជាញឹកញាប់តែងតែជាអ្នក ដែលធ្វើការនៅក្នុងវិស័យឯកជន។ ដូច្នេះនៅទសវត្សឆ្នាំ ១៩៩០ ដល់ដើមទសវត្សរ៍ឆ្នាំ ២០០០ វិទ្យាស្ថានស្រាវជ្រាវ មួយដែលធ្វើការស្រាវជ្រាវលើដំណាំដែលផ្តល់ផលប្រយោជន៍ដល់កសិករក្រីក្របាន រៀបចំរចនាសម្ព័ន្ធគំរោងមួយដែលមានលក្ខណៈដូចជា ភាពជាដៃគូសាធារណៈ និងឯកជន (PPP) ។ សព្វថ្ងៃនេះភាពមាន ប្រៀបនៃវិស័យឯកជនលើកាស្រាវជ្រាវគឺស្ថិតនៅលើបញ្ចេកវិទ្យាខ្ពស់នៃប្រព័ន្ធគ្រប់គ្រងព័ត៌មានជីវវិទ្យា និងទិន្នន័យដែលនេះគឺតែងតែជាឧបសគ្គសំខាន់ក្នុងការស្រាវជ្រាវ របស់វិស័យសាធារណៈ។

**ភាពជាដៃគូពាណិជ្ជកម្មបច្ចេកវិទ្យា**
បច្ចេកវិទ្យាមួយដែលបានបង្កើតឡើងដោយវិស័យសាធារណៈមានដំណើរការរួចទៅហើយ ប៉ុន្តែមិនត្រូវបានផលិតក្នុងបរិមាណ សម្រាប់ការធ្វើពាណិជ្ជកម្មនិងមិនត្រូវបានប្រើប្រាស់ជាទូលំទូលាយនោះទេ។ ការអភិវឌ្ឍន៍ផលិតផលបន្ថែម ការពង្រីកវិសាលភាពទៅដល់កសិករ ការចម្លង បច្ចេកវិទ្យា និងការធ្វើពាណិជ្ជកម្មដំបូង ត្រូវបានគ្រប់គ្រងដោយវិស័យឯកជន។ ចំពោះការធ្វើពាណិជ្ជកម្មដំបូងត្រូវបានអនុញ្ញាតឱ្យទទួលបានប្រាក់ចំណេញពីបច្ចេកវិទ្យា (ដែលជាការលើកទឹកចិត្តដ៏សំខាន់សម្រាប់ការចែកចាយ ឬការផ្សព្វផ្សាយកក្នុង ទ្រង់ទ្រាយធំ) តែស្ថិតក្នុងដែនកំណត់ (ឧទាហរណ៍ក្រោមកិច្ចសន្យាព្រមព្រៀង ផ្តល់អាជ្ញាប័ណ្ណ) ។

បច្ចេកវិទ្យាមួយចំនួនអាចបង្កើនការព្រួយបារម្ភអំពីបញ្ហាសុខភាពនិងបរិស្ថាននៅពេលដែលត្រូវបានចែក ចាយជាលក្ខណៈពាណិជ្ជកម្ម។ភាពជាដៃគូអាចពាក់ព័ន្ធនឹងការ បណ្តុះបណ្តាល ការពង្រឹងសមត្ថភាព និងការការពារផ្សេងទៀតដើម្បីធានាឱ្យ បាននូវការប្រើប្រាស់ប្រកបដោយនិរន្តរភាពនិងសុវត្ថិភាពនៃបច្ចេកវិទ្យា។

**ភាពជាដៃគូក្នុងការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ**
ធ្វើការកំណត់ក្នុងការអនុម័តលើតួអង្គជាច្រើននៅក្នុងខ្សែសង្វាក់តម្លៃសម្រាប់ដំណាំកសិកម្ម បសុសត្វ (រួមទាំងបសុបក្សី) និងផលជលផល (ទាំងការចាប់និងការធ្វើវារីវប្បកម្ម) ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីកំណត់បង្រួមអោយតូចនូវវិសាលភាពនៃភាពជាដៃគូនៃខ្សែសង្វាក់តម្លៃ ចំណុចខាងក្រោមត្រូវបានកំណត់៖

- កម្រិតខាងលើ៖
  ភាពជាដៃគូគ្របដណ្តប់លើការលើកកម្ពស់បច្ចេកវិទ្យាដល់អ្នកផ្គត់ផ្គង់សម្ភារៈដោយផ្ទាល់ដែលជាអ្នកលក់ទៅឱ្យកសិករនិងអ្នកនេសាទ។
  ឧទាហរណ៍ការធ្វើឱ្យប្រសើរឡើងនូវសម្ភារៈដាំដុះសម្រាប់ការបណ្តុះកូនដំណាំឬបច្ចេកទេសបង្កាត់កូនត្រីល្អៗសម្រាប់កន្លែងភ្ញាស់កូនត្រី។
- កម្រិតខាងក្រោម៖
  ភាពជាដៃគូរួមមានការទទួលយកបច្ចេកវិទ្យាសម្រាប់ការដឹកជញ្ជូននិងការរក្សាទុកវត្ថុធាតុដើមសម្រាប់វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ព្រមទាំងការកែច្នៃវត្ថុធាតុដើមទាំងនោះផងដែរ។

## 4. ភាពជាដៃគូសាធារណៈនិងឯកជនក្នុងក្របខ័ណ្ឌតំបន់អាស៊ាន

ក្របខ័ណ្ឌនេះត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាសំខាន់ៗនិងចំណុចដែលជាឧបសគ្គនៅក្នុងកិច្ចសហការរវាងវិស័យសាធារណៈនិងឯកជនសម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម និងព្រៃឈើ។

### 4.1គោលនយោបាយនិងក្របខ័ណ្ឌច្បាប់របស់ភាពជាដៃគូសាធារណៈនិងឯកជន នៅក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម និងព្រៃឈើ

***ក្របខ័ណ្ឌវិនិយោគដែលប្រកបដោយតម្លាភាព ស្ថិរភាព អំណោយផល គួរតែត្រូវបានបង្កើតឡើងសម្រាប់វិស័យសាធារណៈនិងឯកជនដែលចូលរួមក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យានិងកិច្ចសហការលើខ្សែសង្វាក់តម្លៃកសិកម្ម។***

ដោយសារតែភាពស្មុគស្មាញនៃ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលជារឿយៗគ្របដណ្តប់លើផ្នែកផ្សេងៗនៃ គោលនយោបាយជាច្រើន ជាទូទៅ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) មានកម្រិតខុសៗគ្នាទៅតាមច្បាប់ជា ច្រើនកម្រិត បទបញ្ញា និងកម្រិតផ្សេងៗនៃរដ្ឋាភិបាលដែលពាក់ព័ន្ធ។ ដូច្នេះគោលនយោបាយសាធារណៈ បទបញ្ញា និងនីតិវិធីរបស់រដ្ឋដែលជាសមាជិក ត្រូវតែមានភាពស៊ីសង្វាក់និងសមស្របគ្នាដើម្បីធានាឱ្យបានថាគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) នៅក្នុងវិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) អាចត្រូវបានបង្កើតឡើងនិងអនុវត្តប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត ការធានាថានីតិវិធីនិងច្បាប់របស់ រដ្ឋដែលជាសមាជិក ត្រូវមានភាពស៊ីសង្វាក់គ្នា ហើយអាចជួយសម្រួលដល់ការអនុវត្តគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP)  ឆ្លងដែន និងក្នុងតំបន់ ដែលមានគោលដៅក្នុងការធ្វើឱ្យមានការអភិវឌ្ឍន៍និងការវិនិយោគ។

***បរិយាកាសបទប្បញ្ញត្តិដែលមានភាពងាយស្រួលនិងអំណោយផលគួរតែត្រូវបានធានាឱ្យបានសម្រាប់វិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាកសិកម្មដែលមានដូចជាការបង្កើតនិងការចែកចាយរបស់ពួកវា កម្មសិទ្ធិបញ្ញាលើបច្ចេកវិទ្យា និងគោលនយោបាយវិនិយោគលើខ្សែសង្វាក់តម្លៃកសិកម្ម។***

គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលមានតម្លាភាពនឹងចូលរួមចំណែកដល់ការបង្កើតបរិយាកាស ល្អសម្រាប់ការវិនិយោគ ដែលនឹងធានាថាវិស័យឯកជននឹងមានការចាប់អារម្មណ៍ក្នុងការចូលប្រលូកក្នុងទីផ្សារនៃការអភិវឌ្ឍន៍ ការច្នៃប្រឌិតនិងការចែកចាយបច្ចេកវិទ្យាកសិកម្ម ។ សេវាកម្មបទប្បញ្ញត្តិគួរតែត្រូវបានផ្តល់ ជូនប្រកបដោយប្រសិទ្ធភាពចំពោះអតិថិជនមកពីវិស័យឯកជនដែលរួមមាន អ្នកផលិតនិងសហគ្រាសខ្នាតតូចនិងមធ្យម។ រដ្ឋាភិបាលគួរតែធ្វើឱ្យប្រសើរឡើងនូវដំណើរការនៃការអនុវត្តអនុលោមភាព ការរៀបចំឯកសារនិងការធានាការឱ្យបាននូវការអនុម័តនូវសេចក្តីស្នើរសុំ តាមរយៈការចៀសវាងកុំអោយមានការិយាធិបតេយ្យ ភាពរអាក់រអួល និងនីតិវិធីដែលស្មុគស្មាញខ្លាំង។

***បរិយាកាសនៃការវិនិយោគសម្រាប់វិស័យកសិ-ឧស្សាហកម្មគឺជាកត្តាកំណត់ដ៏សំខាន់ការចំពោះការធ្វើឱ្យមាននូវការច្នៃប្រឌិតថ្មីៗនិងការធ្វើពាណិជ្ជកម្មលើបច្ចេកវិទ្យាកសិកម្ម។ ធាតុផ្សំនៃបរិយាកាសអាជីវកម្មល្អរួមមាន៖***

*គោលនយោបាយពន្ធដារ៖* ក្រុមហ៊ុនអាជីវកម្មទូទៅមិនថាជាក្រុមហ៊ុនកសិ-ពាណិជ្ជកម្មខ្នាតធំឬសហគ្រាសធុនតូចនិងមធ្យមនោះទេដែលត្រូវបង់ពន្ធប្រភេទផ្សេងៗដូចជាពន្ធលើប្រាក់ចំណេញសាជីវកម្ម ពន្ធបន្ថែមអាករ ពន្ធរដ្ឋាករ ពន្ធនាំចេញ ចេញពន្ធនាំចូល។ល។ ដោយលែក រដ្ឋដែលជាសមាជិកអាស៊ាន (AMS) បានធ្វើការលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងវិស័យ ចំណីអាហារ កសិកម្ម និង ព្រៃឈើ ចំពោះការស្រាវជ្រាវនិងការ អភិវឌ្ឍន៍ និងការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យមផងដែរ។ ការធ្វើទាំងអស់នេះនឹងមានការជះឥទ្ធិពលដល់ការធ្វើពាណិជ្ជកម្មក្នុងវិស័យបច្ចេកវិទ្យា។ ខណៈពេលដែលការលើកទឹកចិត្តទាំងនេជះឥទ្ធិពលជាទូទៅលើការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) វានៅតែមានសារៈសំខាន់ដែលគោលនយោបាយនៃការលើកទឹកចិត្តធ្វើឱ្យមាននូវការប្រកួតប្រជែងដែលស្មើភាពគ្នា ដើម្បីធានាថានឹងមិនមានផលវិបាកដោយអចេតនានិងផលអវិជ្ជមានដែលកើតឡើងដោយការច្នៃប្រឌិតបច្ចេកវិទ្យា (ឧទាហរណ៍គោលនយោបាយនៃការលើកទឹកចិត្តដែលការពារក្រុមហ៊ុនដែលទទួលបានការគាំទ្រពីកសិករ ពីដៃគូប្រកួតប្រជែងផ្សេងទៀត) ។

*ប្រតិបត្តិការពាណិជ្ជកម្ម៖* រដ្ឋាភិបាលមកពីប្រទេសដែលជាសមាជិកមានតួនាទីត្រួតពិនិត្យប្រតិបត្តិការកម្រិតខាងលើនិងកម្រិតខាងក្រោមដោយយោងតាមគោលនយោបាយនៃការប្រកួតប្រជែងនិងបទបញ្ញាស្តីពីការធ្វើអាជីវកម្មនិងកិច្ចសន្យាកសិកម្មរៀងៗខ្លួន។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយនឹងបទប្បញ្ញត្តិបែបនេះនឹងប៉ះពាល់ដល់ល្បឿននិងវិសាលភាពនៃពាណិជ្ជកម្មបច្ចេកវិទ្យានៅក្នុងវិស័យ វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ(FAF)។ ឧទាហរណ៍នៃបទប្បញ្ញត្តិដែលមានផលប៉ះពាល់ដល់វិស័យឯកជន - ភាពជាដៃគូរបស់អ្នកផលិតមានដូចខាងក្រោម៖

- តម្រូវការផ្សេងៗជាច្រើនសម្រាប់ការចាប់ផ្តើមនិងដំណើរការអាជីវកម្ម ដូចជាការទទួលបានលិខិតអនុញ្ញាតសាងសង់ ការភ្ជាប់ចរន្តអគ្គិសនី ឥណទាន ការចុះឈ្មោះទ្រព្យសម្បត្តិ ការការពារផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុន ការបង់ពន្ធ និងបែបបទនៃការដួញដូរឆ្លងប្រទេស។
- ការធ្វើកសិកម្មតាមកិច្ចសន្យានៅប្រទេសថៃនិងប្រទេសវៀតណាមត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិដោយគោរពតាមសេចក្តីកំណត់ទាក់ទងនឹងគ្រោះថ្នាក់ធម្មជាតិ ការខូចខាតដោយមានសំណង ការដោះស្រាយវិវាទ និងការចុះកិច្ចសន្យាជាមួយអាជ្ញាធរ។
- នៅក្នុងប្រទេសកម្ពុជាអនុក្រឹត្យស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យាធ្វើការគ្របដណ្តប់លើគម្រោងកិច្ចសន្យាដាំដុះ ។ កិច្ចសន្យាត្រូវបានតម្រូវអោយរៀបចំជាលាយលក្ខណ៍អក្សរ មានការបញ្ជាក់យ៉ាងច្បាស់អំពីកិច្ចព្រមព្រៀងលើតម្លៃ ការរួមចំណែករបស់អ្នកទិញនិងអ្នកផ្គត់ផ្គង់ ការប្តេជ្ញាចិត្ត និងការបង្កើតគណៈកម្មការសម្របសម្រួលមួយដើម្បីត្រួតពិនិត្យការបង្កើតនិងការសម្របសម្រួលសម្រាប់ការធ្វើកសិកម្មតាមកិច្ចសន្យា។
- នៅប្រទេសហ្វីលីពីនកសិករដែលមានបំណងចង់ចុះកិច្ចសន្យាជាក្រុមប្រឈមនឹងផលលំបាកក្នុងការចុះឈ្មោះជានីតិបុគ្គលផ្លូវការដោយសារតែតម្រូវការឯកសារ

មានភាពគួរឱ្យធុញទ្រាន់ ទោះបីវាជាកិច្ចសហការ កម្មសិទ្ធិ ភាពជាដៃគូ ឬសាជីវកម្មក៏ដោយ។

*កម្មសិទ្ធិលើអចលនទ្រព្យ៖* កម្មសិទ្ធិលើទ្រព្យសម្បត្តិ លើធនធានធម្មជាតិ ជាពិសេសដីធ្លីត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិយ៉ាងខ្លាំងនៅក្នុងរដ្ឋជាសមាជិក។ ដីជាច្រើនត្រូវបានចាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ។ កម្មសិទ្ធិបញ្ញាដែលស្ថិតក្នុងទំរង់ជាប័ណ្ណប៉ាតង់និងផ្លាកសញ្ញាពាណិជ្ជកម្មអាចផ្តល់នូវចំណែកទីផ្សារកសិ-ពាណិជ្ជកម្មដែលមានសក្តានុពលមួយចំនួន តាមរយៈការធ្វើឱ្យមានលទ្ធភាពក្នុងការចរចាដែលមិនស៊ីចង្វាក់គ្នានៅកម្រិតខាងលើហើយនិងការអនុវត្តន៍ទីផ្សារផ្តាច់មុខនៅកម្រិតខាងក្រោម។ ជាទូទៅស្ថានភាពនៃការប្រកួតប្រជែងដែលមិនមានភាពស្មើភាពគ្នាដែលបង្កើតឡើងដោយបច្ចេកវិទ្យាមិនត្រូវបានហាមឃាត់ទេ។ អ្វីដែលត្រូវបានហាមឃាត់ គឺការរំលោភបំពានលើមុខតំណែងលេចធ្លោរបស់ក្រុមហ៊ុនលេចធ្លោមួយ។ កង្វល់លើកម្មសិទ្ធិបញ្ញាផ្សេងទៀតគឺទាក់ទងនឹងកម្មសិទ្ធិបញ្ញាលើបច្ចេកវិទ្យានិងការអនុវត្តរបស់ក្រុមអ្នកបង្កើតពីដំបូង ព្រោះថាអ្វីដែលពួកគេបានបង្កើតឡើងអាចត្រូវបានយកទៅធ្វើអាជីវកម្មដោយក្រុមហ៊ុនដែលរកប្រាក់ចំណេញដោយមិនបានផ្តល់ផលចំណេញត្រឡប់មកពួកគាត់វិញ។

## 4.2 ក្របខ័ណ្ឌស្ថាប័នជាមួយនិងតួនាទីនិងការទទួលខុសត្រូវ

***ការរៀបចំស្ថាប័នប្រកបដែលមានប្រសិទ្ធភាពដូចជាទីភ្នាក់ងារនិយតករឯករាជ្យដែលមានការកំណត់ការទទួលខុសត្រូវច្បាស់លាស់និងទទួលបានការគ្រប់គ្រងប្រកប ដោយវិជ្ជាជីវៈអំពីអង្គការកសិករ (Fos) សុទ្ធតែជាអ្វីដែលចាំបាច់សម្រាប់ ការលើកកម្ពស់ ការអនុវត្ត ភាពជាដៃគូសាធារណៈនិងឯកជន (PPP)។***

ការរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធភាពដែលមានដូចជាទីភ្នាក់ងារនិយតករឯករាជ្យ ដែលមានទំនួលខុសត្រូវច្បាស់លាស់គឺជាអ្វីដែលចាំបាច់សម្រាប់ការលើកកម្ពស់ការអនុវត្ត ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ឱ្យប្រកបដោយប្រសិទ្ធភាព។ សម្រាប់ក្របខ័ណ្ឌភាពជាដៃគូសហការ សាធារណៈនិងឯកជន ចំណុចនេះពិតជាមានសារៈសំខាន់ជាពិសេសទាក់ទងជាមួយ ក្រសួងកសិកម្ម និងរុក្ខាប្រមាញ់អាស៊ាន ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ និងក្រសួងនិង ទីភ្នាក់ងារពាក់ព័ន្ធដទៃទៀត ដែលមានទំនួលខុសត្រូវចំពោះការស្រាវជ្រាវនិងការអភិវឌ្ឍន៍ ព្រមទាំងការលើកកម្ពស់ការវិនិយោគ។ ការយកចិត្តទុកដាក់ជាពិសែសគួរតែត្រូវបាន ផ្តល់ជូនដល់ការតភ្ជាប់រវាងអាជ្ញាធរថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានព្រម ទាំងពិចារណាលើរចនាសម្ព័ន្ធស្ថាប័នឆ្លងដែននិងតំបន់ផងដែរ។ ក្របខ័ណ្ឌស្ថាប័ន គួរតែកំណត់ឱ្យបានច្បាស់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាល ផ្សេងៗក៏ដូចជាអង្គភាពវិស័យឯកជនក្នុងដំណើរការនៃការបង្កើតនិងអនុវត្តគោល នយោបាយ ភាពជាដៃគូសាធារណៈនិងឯកជន (PPPs) នៅក្នុងវិស័យ ចំណីអាហារ កសិកម្ម និង ព្រៃឈើ ។ តួនាទីនិងការទទួលខុសត្រូវនឹងអាចមានការប្រែប្រួលដោយអាស្រ័យទៅលើប្រភេទ របស់ភាពជាដៃគូសាធារណៈ និងឯកជន (PPP) ។ ដៃគូនីមួយៗត្រូវធានាឱ្យបានថាការរៀបចំរចនាសម្ព័ន្ធរបស់ខ្លួននឹង មានភាពសមស្របទៅតាមមុខងារដែលបានកំណត់។

## 4.3 ការអភិវឌ្ឍន៍ និងការអនុវត្ត ភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់ ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF)

ភាពជាដៃគូសាធារណៈនិងឯកជន ចាំបាច់ត្រូវបានយោងទៅតាមគោលការណ៍សម្រាប់ ការអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយនេះដើម្បីធានាឱ្យបានថាលទ្ធផលដែលចង់បាននិងសុចរិតភាពនឹងត្រូវបានទទួល។
គោលការណ៍ទាំងនេះគួរតែមានភាពសមស្របគ្នាទៅនឹងគោលការណ៍អាស៊ានដែលមានស្រាប់សម្រាប់ក្របខ័ណ្ឌ ភាពជាដៃគូសាធារណៈនិងឯកជន ។ គោលការណ៍ខាងក្រោមត្រូវបានណែនាំ៖

***របៀបវារៈនៃការស្រាវជ្រាវកសិកម្មនិងផែនការវិនិយោគជាមួយឧបករណ៍វិភាគសមស្របដែលមានដូចជាការកំណត់អាទិភាពនិងការវិភាគផ្លូវនៃផលប៉ះពាល់។***

ការវាយតម្លៃអំពីភាពជាដៃគូរវាងក្រុមពិគ្រោះយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ (CGIAR)
ជាមួយវិស័យឯកជនបានរកឃើញថាការស្រាវជ្រាវជាច្រើនដែលត្រូវបានធ្វើ
បានរកឃើញថាមានការជះឥទ្ធិពលទៅលើជីវិតរបស់អ្នកផលិត
និងអ្នកប្រើប្រាស់ក្រីក្រមិនសូវត្រូវបានគេយកចិត្តទុកដាក់។
មិនមែនគ្រប់បច្ចេកវិជ្ជាឬយុទ្ធសាស្ត្រច្នៃប្រឌិតដែលមាននៅលើតុអាចសុទ្ធតែទទួលបានមូលនិធិគ្រប់គ្រាន់នោះទេ
ដូច្នេះអាទិភាពត្រូវតែបានកំណត់ដោយផ្អែកលើការចំណាយដែលប្រកបដោយប្រសិទ្ធភាពដែលនឹងទទួលបានលទ្ធផលនិងផលប៉ះពាល់វិជ្ជមានជាក់ស្តែង។

***ការជ្រើសរើសគម្រោងនិងរបៀបនៃការសហការគ្នាគួរតែផ្អែកលើដំណើរការពិគ្រោះយោបល់ដែលមានការចូលរួមពីភាគីពាក់ព័ន្ធ។***

ការកំណត់អាទិភាពនិងការវាយតម្លៃផលប៉ះពាល់អាចចាប់ផ្តើមតាមរយៈការវាយតម្លៃលើតុដោយផ្អែកលើទិន្នន័យស្រាវជ្រាវពាក់ព័ន្ធដែលអាចរកបាន និងការផ្តល់ព័ត៌មានពីបុគ្គលសំខាន់ៗមួយចំនួន។ ទោះជារបៀបវារៈរបស់ ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) មានភាពទូលំទូលាយយ៉ាងណាក៏ដោយ បូកផ្សំជាមួយរបៀបនៃការសហការគ្នាដែលចង់បានគួរតែត្រូវបានឆ្លងកាត់ដំណើរការនៃការពិគ្រោះយោបល់យ៉ាងម៉ត់ចត់។
ដំណើរការពិគ្រោះយោបល់គួរតែខិតខំដើម្បីឱ្យមានការចូលរួមយ៉ាងពិតប្រាកដពីវិស័យផ្សេងៗ និងសហគមន៍ដែលនឹងទទួលបានផលប៉ះពាល់ដោយផ្ទាល់ ពីបច្ចេកវិទ្យាថ្មីៗនោះ។

***ការរចនាគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលនឹងមានការវិនិយោគដ៏សំខាន់ទាមទារឱ្យមាន ការវិភាគប្រាក់ចំណាយនិងការវិភាគពេញមួយជីវិត។***

ខណៈពេលដែលសកម្មភាពស្រាវជ្រាវមួយចំនួនអាចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនជាមួយនិងការចំណាយតិចតួច
សកម្មភាពស្រាវជ្រាវខ្លះទៀតអាចត្រូវការការចំណាយខ្ពស់ដែលទាមទារអោយមានការវិនិយោគពីដៃគូសាធារណៈឬឯកជន។
ចំពោះទំហំនៃការវិនិយោគនេះគឺអាស្រ័យលើការវិភាគយ៉ាងម៉ត់ចត់និងជាប្រព័ន្ធដែលត្រូវបានធានាដោយវិធីសាស្ត្រវិភាគពេញមួយជីវិតនិងតម្លៃសម្រាប់ការចំណាយ។

***ល័ក្ខខ័ណ្ឌនៃភាពជាដៃគូរវាងសាធារណៈនិងឯកជនត្រូវធានាឱ្យបានត្រឹមត្រូវនូវការលើកទឹកចិត្តទាក់ទងនឹងការចែករំលែកហានិភ័យថ្លៃដើមនិងអត្ថប្រយោជន៍នៃបច្ចេកវិទ្យាកសិកម្ម។***

គោលដៅជាក់លាក់មួយរបស់ ភាពជាដៃគូសាធារណៈនិងឯកជន (PPP)
គឺជាការធ្វើអោយហានិភ័យអាចក្លាយទៅជាលទ្ធភាពដែលទទួលបានអត្ថប្រយោជន៏។
ជាឧទាហរណ៍វិស័យសាធារណៈអាចនឹងផ្លាស់ប្តូរពាណិជ្ជកម្មនូវបច្ចេកវិទ្យាដែលជោគជ័យមួយទៅអោយវិស័យឯកជនជាថ្នូរនឹងការទទួលបានមូលនិធិមួយផ្នែកនៃថ្លៃដើមពីដៃគូវិនិយោគឯកជន។

ប្រសិនបើដូច្នេះដៃគូឯកជនទំនងជាទាមទារអោយពួកគេមានសិទ្ធក្នុងការចូលរួមក្នុងការរៀបចំគម្រោងនិងប្រតិបត្តិការគម្រោង។ ហេតុដូច្នេះដៃគូឯកជនត្រូវបានលើកទឹកចិត្តដើម្បីបង្កើនឱកាសនៃការទទួលបានភាពជោគជ័យពីការស្រាវជ្រាវ (អាស្រ័យលើកម្រិតនៃការចំណាយលើការវិនិយោគ) ។ វាត្រូវតែមានការយកចិត្តទុកដាក់ក្នុងការពនិត្យអោយបានច្បាស់ថាកិច្ចសន្យានេះនឹងមានមានភាពលំអៀងដែលនឹងផ្តល់អត្ថប្រយោជន៏ទៅកាន់ភាគីតែម្ខាងនោះទេ។ ឧទាហរណ៍កិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណផ្តាច់មុខសម្រាប់ដៃគូឯកជនដែលមានរយៈពេលយូរពេកនឹងអនុញ្ញាតឱ្យពួកគេទទួលបានប្រាក់ចំណេញច្រើនលើសលប់ក្នុងរយៈពេលវែង។

***ធ្វើការណែនាំនូវយន្តការនិងការការពារដើម្បីធានាការទទួលបាននូវផលប្រយោជន៍របស់កសិករខ្នាតតូច និងសហគ្រាសធុនតូចនិងមធ្យមស្របពេលដែលនៅតែរក្សាបាននូវភាពទាក់ទាញនៃភាពជាដៃគូចំពោះវិស័យឯកជន។***

ផ្នែកមួយទៀតនៃការចែករំលែកផលប្រយោជន៍គឺដើម្បីធានាថាអ្នកផលិតខ្នាតតូចនិងមធ្យមនៅក្នុងខ្សែសង្វាក់តម្លៃទទួលបានចំណែកសមរម្យនៃអត្ថប្រយោជន៍នៃការច្នៃប្រឌិតកសិកម្មរបស់ពួកគេ។ កម្មសិទ្ធិបញ្ញានិងកិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណគួរតែត្រូវបានរៀបចំឡើងដើម្បីជាការលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនទន្ទឹមនឹងការផ្សព្វផ្សាយអត្ថប្រយោជន៍នៃការបង្កើតថ្មីដល់អ្នកផលិតខ្នាតតូចនិងមធ្យមក៏ដូចជាអ្នកប្រើប្រាស់ផងដែរ។ ឧបករណ៍ ចំណុចមួយចំនួនដូចខាងក្រោមអាចត្រូវបានពិចារណាៈ

- ការផ្តល់អាជ្ញាប័ណ្ណមិនផ្តាច់មុខ
- •ការផ្តល់អាជ្ញាប័ណ្ណមានរយៈពេលកំណត់
- ការកំណត់ពិដានតម្លៃចាំបាច់សម្រាប់បច្ចេកវិទ្យាថ្មី
- ការបញ្ចុះតម្លៃជាចាំបាច់ឬការឧបត្ថម្ភធនដល់កសិករនិងអ្នកនេសាទដែលខ្វះខាតហើយទទួលយកបច្ចេកវិទ្យានេះ។

ការអនុវត្តនេះបានបង្កើតឡើងដោយអាស្រ័យលើកម្លាំងរុញច្រានជាថ្មីសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដែលបានធ្វើការប្តេជ្ញាចិត្តក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសតាមរយៈការគាំទ្រក្នុងទម្រង់នៃការអភិវឌ្ឍន៍និងការផ្ទេរបច្ចេកវិទ្យាដូចជាបច្ចេកវិទ្យាកសិកម្មអាកាសធាតុឆ្លាតវៃ (CSA) លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងការកសាងសមត្ថភាពឆ្ពោះទៅរកការកាត់បន្ថយការចំណាយថ្លៃដើមក្នុងការសម្របខ្លួននិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

***ប្រព័ន្ធសម្រាប់ត្រួតពិនិត្យសកម្មភាពនិងលទ្ធផលក៏ដូចជាការវាយតម្លៃលទ្ធផលនិងផលប៉ះពាល់គួរតែត្រូវបានបង្កើតឡើងដើម្បីរក្សាគណនេយ្យភាពនិងយកបទពិសោធន៍ដែលទទួលបានដើម្បីធ្វើឱ្យការអនុវត្តគម្រោងវគ្គក្រោយកាន់តែមានភាពល្អប្រសើរ។***

ដោយសារតែគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ជាគម្រោងថ្មីថ្មោងនៅក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) ការស្រាវជ្រាវនិងការ អភិវឌ្ឍន៍ ទំនងជាមានបញ្ហា និងផលប៉ះពាល់ក្នុងការរចនា និងការអនុវត្តគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) នាពេលបច្ចុប្បន្ន និងអនាគត។ វាមានសារៈសំខាន់ណាស់ក្នុងការបញ្ចូលតំណើរការនៃការត្រួតពិនិត្យនិងការវាយតម្លៃទៅក្នុងការរចនាសម្ព័ន្ធគម្រោងគ្រប់ផ្នែករបស់គម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ។ ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃគួរតែត្រូវបានបង្កើតឡើងដោយផ្អែកលើក្របខ័ណ្ឌឡូជីខលនិងទ្រឹស្តីនៃការផ្លាស់ប្តូររបស់ ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ ។ ចំណុចដែលត្រូវពិភាក្សាមានដូចជាៈ

- វត្ថុធាតុដើម (ចំណាយ)
- សកម្មភាពដូចដែលបានកំណត់នៅក្នុងផែនការអនុវត្ត
- លទ្ធផលឬសមិទ្ធផលដែលអាចវាស់វែងបានពីការអនុវត្តគម្រោង។ ទាំងនេះរួមបញ្ចូលទាំងសូចនាករនៃការអនុវត្តនិងរង្វាស់ស្ទង់នៃការអនុវត្តដូចជា

(អាស្រ័យលើគម្រោងជាក់ស្តែង)៖
ចំនួនកសិករដែលទទួលបានការបណ្តុះបណ្តាលអំពីកសិកម្មអាកាសធាតុឆ្លាតវៃ
ថាតើពូជរុក្ខជាតិថ្មីត្រូវបានបង្កើតឡើងតាមលក្ខណៈដែលចង់បានឬទេ
(ឧទាហរណ៍ភាពធន់ជាមួយនិងកត្តាចង្រៃឬភាពធន់នឹងគ្រោះរាំងស្ងួត)
ចំនួនអ្នកនេសាទដែលប្រើឧបករណ៍នេសាទប្រកបដោយនិរន្តរភាព ។ ល។
លទ្ធផលក៏គួរត្រូវបានវាយតម្លៃដោយផ្អែកទៅលើពេលវេលាដែលបានកំណត់នៅក្នុងផែនការអនុវត្តផងដែរ។

ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃគួរតែបង្ហាញអំពីការបញ្ជាក់និងការវាស់ស្ទង់លទ្ធផលនិងផលប៉ះពាល់ផងដែរ។ ការធ្វើដូចនេះត្រូវតម្រូវឱ្យមានវិធីសាស្ត្រពេញមួយជីវិត (whole-of-life approaches )
ដើម្បីពិនិត្យមើលការស្រូបយក និងការទទួលយកបច្ចេកវិទ្យានិងការអនុវត្តដែលត្រូវបានណែនាំ។
ការពង្រីកវិសាលភាពនៃប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃនាំឱ្យមានការកំណត់នូវការអនុវត្តល្អនិងមេរៀនដែលបានសិក្សាសម្រាប់ការបន្តអនុវត្តគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)
នាពេលអនាគតនៅក្នុង ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) ។
ការរៀបចំប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃឱ្យបានល្អិតល្អន់គឺជាភារកិច្ចរបស់វិស័យសាធារណៈព្រោះវាជាដៃគូដែលទទួលខុសត្រូវដោយផ្ទាល់ចំពោះសាធារណជន។
ទោះជាយ៉ាងណាក៏ដោយដៃគូឯកជនអាចបើកចំហរឬអាចរួមចំណែកក្នុងការអនុវត្ត ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃដែលជាផ្នែកមួយនៃអាជីវកម្មដែលមានបរិយាប័ន្ន ឬ កត្តាកំណត់នៃទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនខ្លួន។

## 4.4 តំបន់នៃកិច្ចសហប្រតិបត្តិការ

វិស័យអាទិភាពដែលត្រូវទទួលបានការអនុវត្តគម្រោងនិងវិស័យអាទិភាពផ្សេងទៀត
ដែលនឹងត្រូវចូលរួមហើយនឹងជំហានតំណាក់កាលផ្សេងៗនៅក្នុងខ្សែសង្វាក់តម្លៃនៃផលិតផលស្បៀងអាហារ កសិកម្ម និងព្រៃឈើ(FAF)  ត្រូវតែទទួលបានការព្រមព្រៀងគ្នា
ហើយគួរតែគិតគូរអំពីបញ្ហាបច្ចេកវិទ្យាដែលត្រូវប្រើប្រាស់ ប្រព័ន្ធផលិតកម្ម
និងបច្ចេកវិទ្យាមុននិងក្រោយការប្រមូលផល និងដំណើរការកម្រិតខាងក្រោម (downstream processing) ។ សម្រាប់ការផ្តល់អាទិភាព គោលបំណងរួមនៃក្របខ័ណ្ឌ
គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)
គឺដើម្បីបង្កើនការវិនិយោគរួមគ្នាក្នុងការអនុម័តបច្ចេកវិទ្យាប្រកបដោយនិរន្តរភាព
និងចក្ខុវិស័យរបស់ វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ដែលមាននូវ
ភាពប្រកួតប្រជែង បរិយាប័ន្ន ភាពធន់ និងការអភិវឌ្ឍន៍ប្រកបដោយ
និរន្តរភាពរបស់ វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF)
ក៏គួរតែត្រូវបានយកមកពិចារណាផងដែរ។ ហេតុដូច្នេះ គោលដៅសំខាន់ៗរបស់
គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) គួរតែស្ថិតនៅក្នុងវិស័យ
និងដំណើរការផ្សេងៗដែលពាក់ព័ន្ធខ្លាំងបំផុតដើម្បីសម្រេចបាននូវលទ្ធផលនិងគម្រោង
វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ឆ្នាំ២០២៥ ។
ផ្នែកផ្សេងៗនៃកិច្ចសហប្រតិបត្តិការដូចខាងក្រោមត្រូវបានកំណត់ដោយពិចារណាលើបទពិសោធន៍នៅក្នុងសមាគមអាស៊ានរួមជាមួយគម្រោង វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF)  ឆ្នាំ ២០២៥៖

i) ការ អភិវឌ្ឍន៍និងការធ្វើពាណិជ្ជកម្មលើប្រភេទពូជថ្មីៗនៃរុក្ខជាតិនិងសត្វ ដែលមានដូចជា៖ ដំណុះគ្រាប់ពូជ និងការបែងចែកគ្រាប់ពូជ ការបណ្តុះបណ្តាលនិងការផ្លាស់ប្តូរអ្នកជំនាញផ្នែកហ្សែន ការផ្សព្វផ្សាយពូជដែលមានភាពធន់ទៅនឹងកត្តាចង្រៃ និងជំងឺរបស់ដំណាំដែលមានតម្លៃអាហារូបត្ថម្ភខ្ពស់ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

ii) ការច្នៃប្រឌិតថ្មីក្នុងវត្ថុធាតុដើមក្នុងវិស័យកសិកម្ម និងប្រព័ន្ធផលិតកម្ម និងខ្សែសង្វាក់តម្លៃដែលផ្តោតជាពិសេសលើការអនុវត្តកសិកម្មល្អបំផុត សុវត្ថិភាពម្ហូបអាហារ និងសន្តិសុខស្បៀងនិងការប្រែប្រួលអាកាសធាតុ។

iii) គាំទ្រដល់ការ អភិវឌ្ឍន៍និងការអនុម័តប្រើប្រាស់តាមខ្សែសង្វាក់តម្លៃនៃបច្ចេកវិទ្យានិងការបង្កើតថ្មី ដោយភ្នាក់ងារចំណីអាហារ កសិកម្មនិងព្រៃឈើ ហើយនឹង សហគ្រាសខ្នាតតូចនិងមធ្យម ។

ទម្រង់ទូទៅរបស់ភាពជាដៃគូ គឺការតម្រូវអោយវិស័យឯកជនបរិច្ចាគបច្ចេកវិទ្យា ដែលមានជាកម្មសិទ្ធិរបស់ពួកគេ ខណៈដែលវិស័យសាធារណៈផ្តល់នូវដំណុះគ្រាប់ពូជ មន្ទីរពិសោធន៍ កម្លាំងពលកម្មនិងចំណេះដឹងជីវសាស្ត្រដែលពាក់ព័ន្ធ។

នៅក្នុងសង្វាក់តម្លៃទាំងមូល ការបង្កើតថ្មីដើម្បីលើកកម្ពស់សុវត្ថិភាពម្ហូបអាហារ

ការបង្កើតប្រព័ន្ធតាមដាន និងការកែលម្អគុណភាពក្រោយប្រមូលផលគឺជាចំណុចសំខាន់ៗនៃកិច្ចសហប្រតិបត្តិការរវាងអ្នកផលិត ស្ថាប័នអ្នកទិញ និងរដ្ឋាភិបាល។ ភាពជាដៃគូដែលបង្កើតឡើងតាមរយៈការសន្ទនា ការបង្កើតបណ្តាញ និងការសម្របសម្រួលមិនថាផ្លូវការឬក្រៅផ្លូវការ អាចផ្តល់នូវការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ អនាម័យ និងភូតគាមអនាម័យចំណីអាហារ (SPS) (ឧទាហរណ៍មន្ទីរពិសោធន៍រោគវិនិច្ឆ័យ) និងការសម្រួលពាណិជ្ជកម្ម (ឧទាហរណ៍ការត្រួតពិនិត្យនិងទទួលស្គាល់ ភូតគាម អនាម័យចំណីអាហារ)។

ឱកាសជាច្រើនសម្រាប់កិច្ចសហការក៏មានច្រើនផងដែរនៅក្នុងតំបន់ដែលមានកិច្ចសហប្រតិបត្តិការ។ ក្រុមហ៊ុនអាជីវកម្មកសិ-ពាណិជ្ជកម្មធំៗ អាចនឹងចូលរួមក្នុងទីផ្សារផ្នែកខាងក្រោម(ជាពិសេសសម្រាប់ការនាំចេញ) ឬការផ្គត់ផ្គង់សេវាកម្មឡជីស្ទីកសំខាន់ៗ (ដូចជាកន្លែងត្រជាក់សម្រាប់ទុកទំនិញ) ។ ទន្ទឹមនឹងនេះ សហគ្រាសខ្នាតតូចនិងមធ្យម អាចផ្តល់សេវាកម្មការកែច្នៃនិងវេចខ្ចប់កម្រិតបឋមបានផងដែរ។ ភាពជាដៃគូរួមគ្នាជាមួយវិស័យសាធារណៈអាចគាំទ្រដល់ការកាត់បន្ថយការខាតបង់ និងការខ្ជះខ្ជាយក្រោយការប្រមូលផលតាមរយៈការទទួលយកនូវការអនុវត្តដែលនិងបច្ចេកវិទ្យាសម្រាប់ក្រោយពេលប្រមូលផលល្អប្រសើរជាងមុន ។ ការស្រាវជ្រាវកែច្នៃម្ហូបអាហារតាមរយៈស្ថាប័នស្រាវជ្រាវរបស់គ្រឹះស្ថានសិក្សានិងបែបវិទ្យាសាស្ត្រ គម្រោងបង្កើតបច្ចេកវិទ្យា និងការបណ្តាក់ទុនរួមគ្នា ត្រូវបានរកឃើញថាបានកើតមាននៅទូទាំងប្រព័ន្ធនៃការច្នៃប្រឌិតកសិកម្មនៅក្នុងអាស៊ាន។

## 4.5 នីតិវិធីសម្រាប់ការអភិវឌ្ឍគម្រោងនិងការអនុវត្ត

យោងតាមគោលការណ៍របស់គម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ការជ្រើសរើសគម្រោង សម្រាប់អភិវឌ្ឍន៍និងការអនុវត្ត គំរោង ហើយនិងព័ត៌មានលម្អិតអំពីនីតិវិធីដែលបានព្រមព្រៀង អាចរកបាននៅក្នុង គោលការណ៍អាស៊ានសម្រាប់ក្របខ័ណ្ឌ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ។ ក្របខ័ណ្ឌនេះគ្របដណ្តប់លើវិធីសាស្ត្រលទ្ធកម្ម និងការគ្រប់គ្រងដំណើរការ របស់គម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ហើយផ្អែកលើគោលការណ៍អត្ថប្រយោជន៍ដែលល្អបំផុតសម្រាប់ការចំនាយ និងការបែងចែកហានិភ័យប្រកបដោយប្រសិទ្ធភាពបំផុត។

នីតិវិធីគួរតែរួមបញ្ចូលនូវការណែនាំច្បាស់លាស់អំពីគំរូនៃការចែករំលែកអត្ថប្រយោជន៍ (ឧទាហរណ៍ប្រាក់សួយសារនិងកម្មសិទ្ធិបញ្ញា) នៅក្នុង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ក៏ដូចជាវិធានសម្រាប់ការបង្ហាញ និងការចែករំលែកព័ត៌មាន ការដោះស្រាយវិវាទ និង នីតិវិធីពាក់ព័ន្ធ ផ្សេងទៀតដែលត្រូវយកមកពិចារណាដើម្បីធានាឱ្យបាននូវលទ្ធផលដែលយើងចង់ទទួលបានពីគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP)។

**ការជ្រើសរើសគម្រោង៖**
ការជ្រើសរើសគម្រោងដំបូងគួរតែត្រូវបានធ្វើឡើងក្រោយពីទទួលបានពត៌មានអំពីចំណុចមួយចំនួនដូចជាវត្ថុធាតុដើមដែលរំពឹងទុក សកម្មភាពនានា លទ្ធផល ប្រសិទ្ធភាព និងចំណុចចុងក្រោយគឺផលប៉ះពាល់ ដែលជាសូចនាករកំណត់នៃការផ្លាស់) (ឧទាហរណ៍ ប្រាក់ចំណូលគ្រួសារ ភាពក្រីក្រ ស្ថានភាពអាហារូបត្ថម្ភ។ល។)។

លទ្ធផលត្រូវមានភាពសមស្របទៅតាមបច្ចេកវិទ្យាដែលកំពុងត្រូវបានបង្កើតឡើង)។ ការពិចារណាដ៏សំខាន់មួយនៅក្នុងការជ្រើសរើសគម្រោង គឺជាការពាក់ព័ន្ធគ្នារវាង លទ្ធផលនិងប្រសិទ្ធភាពដែលបានគ្រោងទុកក្នុងការលើកកម្ពស់ កសិកម្មអាកាសធាតុឆ្លាតវៃ និង ភាពធន់នឹងអាកាសធាតុដែលនាំឱ្យ មានការការពារនិងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់គ្រួសារកសិករដែលអាស្រ័យផលលើការធ្វើកសិកម្ម នេសាទ និងទទួលផលពីអនុផលព្រៃឈើ។ ហើយពួកគេគឺជាជនងាយរងគ្រោះបំផុតដោយសារតែការប្រែប្រួលអាកាសធាតុ។ ការរំពឹងទុកទាំងនេះ គាំទ្រនូវទ្រឹស្តីនៃការផ្លាស់ប្តូរដែលត្រូវបានដាក់ចេញ ដោយគម្រោងអភិវឌ្ឍន៍បច្ចេកវិទ្យា។ ការរចនាគម្រោងស្រាវជ្រាវ តែងតែត្រូវបានបញ្ចប់នៅពេលដែលទទួលបានលទ្ធផល ដោយមិនចាំបាច់គិតគូរបន្ថែមអំពីការទទួលយករបស់អ្នកប្រើបច្ចេកវិទ្យា ហើយនិងលទ្ធផលដែលទទួលបានពីការជ្រើសរើស បច្ចេកវិទ្យា ទាំងនោះទេ។ គម្រោងត្រូវតែត្រូវបានជ្រើសរើសមិនត្រឹមតែផ្អែកលើគុណសម្បត្តិនៃបច្ចេកវិទ្យាដែលបានបង្កើតនិងលទ្ធភាពជោគជ័យនៃការស្រាវជ្រាវនោះទេ។ ការធ្វើសេចក្តីសម្រេចចិត្តក៏ត្រូវមានការសំលឹងទៅអោយបានឆ្ងាយ ដោយធានាថាបច្ចេកវិទ្យានោះគួរតែត្រូវបានចែកចាយ  មានការទទួលយកបានទូលំទូលាយ និងដើម្បីផលប្រយោជន៍របស់អ្នកប្រើប្រាស់។

ចំណុចទី ២  គម្រោងនេះត្រូវទទួលបានការវិភាគពីប្រភេទផ្សេងៗ គ្នាក្នុងការវាយតម្លៃជម្រើសរបស់គម្រោង។ ប្រភេទសំខាន់មួយនៃការវិភាគគឺ ការវិភាគការចំណាយថ្លៃដើមនិងអត្ថប្រយោជន៍។ គ្រាន់តែលទ្ធផលនៃការវិភាគផលប៉ះពាល់វិជ្ជមាននៅកម្រិតគ្រួសារដែលតែមួយមុខគឺមិនគ្រប់គ្រាន់ដើម្បីជាហេតុផលក្នុងការវិនិយោគលើការស្រាវជ្រាវនោះទេ។ អត្ថប្រយោជន៍ដែលរំពឹងទុកគួរតែមានមតម្លៃខ្ពស់ជាងថ្លៃដើម។ ការវិភាគថ្លៃ ការចំណាយថ្លៃដើមនិងអត្ថប្រយោជន៍ទាក់ទងនឹងបច្ចេកទេសសំខាន់ពីរគឺការបញ្ចុះតម្លៃទាំងអត្ថប្រយោជន៍និងថ្លៃដើម និងការវាយតំលៃអត្ថប្រយោជន៍និងថ្លៃដើម។ ទំរង់នៃការវិភាគផ្សេងទៀតដើម្បីបំពេញបន្ថែមនូវការវាយតម្លៃការចំណាយ ឬជំនួសវានៅពេលដែលមានលក្ខណៈមិនសមស្របរួមមាន៖ ការវិភាគជម្ទតា ការវិភាគប្រសិទ្ធភាពចំណាយ  និងការវិភាគពហុលក្ខណៈវិនិច្ឆ័យ។

**វិធីសាស្ត្រនៃការធ្វើលទ្ធកម្ម៖** ការរៀបចំ គម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP)ដែលត្រូវបានស្នើឡើងគួតែត្រូវបានឆ្លងកាត់ការសាកល្បង ការវិភាពតម្លៃជាមួយនិងអត្ថប្រយោជន៏។ ការវិភាគនេះគឺជាការប្រៀបធៀបរវាងវិធីសាស្ត្រនៃការធ្វើលទ្ធកម្មដែលបានស្នើសុំជាមួយជម្រើសវិធីសាស្ត្រលទ្ធកម្មផ្សេងទៀតដើម្បីផ្ទៀងផ្ទាត់ថាតើការរៀបចំដែលបានស្នើឡើងបានផ្តល់នូវអត្ថប្រយោជន៍ល្អបំផុតដល់រដ្ឋាភិបាលនិងសង្គមទាំងមូលពិតមែនដែរឬទេ។

ការប្រៀបធៀបអាចធ្វើឡើងដោយប្រើទិន្នន័យគុណភាពទិន្នន័យបរិមាណឬក៏ទាំងពីរ។ ការវិភាគគុណភាពបានបង្ហាញពីវិធីសាស្ត្រលទ្ធកម្មដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យសមស្របដូចជា៖

- ភាពពាក់ព័ន្ធនៃគម្រោងទៅនឹងគោលដៅនៃការអភិវឌ្ឍន៍ដែលប្រកបដោយចិរភាពនិង ការជំរុញយុទ្ធសាស្ត្រនៃចក្ខុវិស័យនិងផែនការយុទ្ធសាស្ត្រសម្រាប់វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ដូចជាការអភិវឌ្ឍន៍ កសិកម្មអាកាសធាតុឆ្លាតវៃ និងភាពធន់នឹងអាកាសធាតុ។
- ភាពសាមញ្ញក្នុងការកំណត់អត្តសញ្ញាណនិងការបែងចែកសកម្មភាពគម្រោង តួនាទី និងការទទួលខុសត្រូវ
- សេវាកម្មដែលមានបទដ្ឋានស្តង់ដារល្អដែលមាននៅលើទីផ្សារដែលមានការប្រកួតប្រជែង គួរតែត្រូវបានដាក់អោយមានការដេញថ្លៃដែលមានលក្ខណៈ ប្រកួតប្រជែង
- គម្រោងដែលត្រូវការបច្ចេកវិទ្យាឬដំណើរការដែលមានកម្មសិទ្ធិអាចតម្រូវឱ្យ មានកិច្ចសន្យាការងារដោយផ្ទាល់
- ហានិភ័យគួរតែត្រូវបានបែងចែកឱ្យសមស្របទៅនឹងអត្ថប្រយោជន៍ដែលត្រូវទទួលបាន។

ការវិភាគបរិមាណរបស់ការវាយតំលៃការចំណាយ មានការទាក់ទងនឹងសំណុំនៃការវិភាគថ្លៃដើមផលិតកម្មរបស់វិធីសាស្ត្រលទ្ធកម្មដែលជាជម្រើសផ្សេ

ងៗទៀត។ ឧទាហរណ៍ ការស្រាវជ្រាវនិងការអភិវឌ្ឍន៍ដែល ធ្វើឡើងក្នុងស្រុក ប្រៀបធៀបទៅនឹងគម្រោង ភាពជាដៃគូសាធារណៈ និងឯកជន (PPP) ដែលបានស្នើសុំ។

ក្នុងករណីដែលគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ត្រូវបាន គេចាត់ទុកថាជាជម្រើសដែលទទួលបានការពេញចិត្តជំហានបន្ទាប់គឺការសម្រេច ចិត្តលើបែបបទ និងនីតិវិធីនៃការអនុវត្តគម្រោងនេះ។ នៅក្នុងប្រភេទ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ បែបបទរួមមាន៖ បង្កើត-ប្រតិបត្តិការ-ផ្ទេរ; សាងសង់-ផ្ទេរ សាងសង់-កម្មសិទ្ធ-ប្រតិបត្តិការ-ប្រតិបត្តិការ-ផ្ទេរ បង្កើត-កម្មសិទ្ធ-ប្រតិបត្តិការ ជាដើម។

**ចំពោះភាពជាដៃគូផ្នែកធនធាន** ការអនុវត្តគឺជាការទទួលខុសត្រូវរបស់ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS) ។  ការស្រាវជ្រាវនិងការអភិវឌ្ឍន៍

និងសកម្មភាពពាណិជ្ជកម្មនឹងត្រូវកំណត់និងរៀបចំឡើងដោយ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (NARS) ។ ភាពជាដៃគូនឹងបញ្ជាក់ ពីកាតព្វកិច្ចរបស់ដៃគូឯកជននិងរយៈពេលវេលានៃការគាំទ្រ។ ប្រសិនបើជាការផ្តល់មូលនិធិ បែបបទនៃគម្រោងនឹងបញ្ជាក់ពីចំណុចជោគជ័យ សំខាន់ៗនៃគម្រោងនឹងកម្មវិធីនៃការបញ្ចេញមូលនិធិ។ ប្រសិនបើមានជំនាញ គម្រោងនឹងបញ្ជាក់ពីការរៀបចំរបស់ម្ចាស់ផ្ទះដែលជាប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ(NARS) ហើយលទ្ធផលដែលរំពឹងទុកថានឹងទទួលបានពីការទទួលអ្នកជំនាញផ្នែក ឯកជន។

**សម្រាប់កិច្ចសហការស្រាវជ្រាវតាមកិច្ចសន្យានិងកាស្រាវជ្រាវចំណេះដឹងមូលដ្ឋាន**
សកម្មភាពនិងព្រឹត្តិការណ៍សំខាន់ៗនឹងត្រូវមានផែនការរួមគ្នាដោយដៃគូ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិនិងដៃគូឯកជន។ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗទាក់ទង នឹងបរិក្ខារ បុគ្គលិក និងតួនាទីសកម្មភាពនឹងត្រូវបានបញ្ជាក់ជាមុន។ បន្ទាប់ មកផែនការនេះ នឹងត្រូវបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងកិច្ចសន្យា។

**សម្រាប់ភាពជាដៃគូពាណិជ្ជកម្ម**
បច្ចេកវិទ្យាថ្មីមួយត្រូវបានសន្មតថាត្រូវបានបញ្ចប់និងជាកម្មសិទ្ធិរបស់ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ ដូចដែលបានបញ្ជាក់ជាផ្លូវការក្នុងប៉ាតង់។ អ្វីដែលនៅសេសសល់គឺការ អភិវឌ្ឍន៍បច្ចេកវិទ្យាដែលនាំទៅដល់ការធ្វើពាណិជ្ជកម្ម។ ដំណើរការនេះតម្រូវឱ្យមានជំហានដូចខាងក្រោម:

- កិច្ចព្រមព្រៀងទៅវិញទៅមកស្តីពីការកំណត់សិទ្ធិនិងការទទួលខុសត្រូវរបស់ដៃគូឯកជន (ឧទាហរណ៍អាជ្ញាប័ណ្ណបច្ចេកវិទ្យា រយៈពេលនៃអាជ្ញាប័ណ្ណ ការទទួលបានបច្ចេកវិទ្យាពីសំណាក់អ្នកផលិតខ្នាតតូច។ល។ )
- ការរៀបចំគម្រោងសម្រាប់សកម្មភាពនិងព្រឹត្តិការណ៍សំខាន់ៗសម្រាប់ការ ធ្វើពាណិជ្ជកម្ម
- ការរៀបចំសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងអង្គការកសិករ
- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាផ្លូវការរវាងដៃគូ (រួមទាំងអង្គការសង្គមស៊ីវិល អង្គការកសិករ ដែលពាក់ព័ន្ធ) ការអនុវត្ត និងការត្រួតពិនិត្យ។

ជាចុងក្រោយ សម្រាប់ភាពជាដៃគូអភិវឌ្ឍន៍សង្វាក់តម្លៃបច្ចេកវិទ្យាដែលមានស្រាប់ ហើយត្រូវបានកាន់កាប់ដោយដៃគូឯកជន (ឬជាកម្មសិទ្ធិរួមគ្នា)ហើយត្រូវបាន ធ្វើពាណិជ្ជកម្មក្នុងកម្រិតខ្លះរួចហើយ។អ្វីដែលនៅសេសសល់គឺការធ្វើឱ្យ ប្រសើរឡើង នូវបច្ចេកវិទ្យាដើម្បីដោះស្រាយឧបសគ្គចំពោះការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ។ ការអនុវត្តនេះតម្រូវឱ្យមានជំហានជាតំណាក់កាលដូចខាងក្រោមដែលមានភាពស្របគ្នាយ៉ាងខ្លាំង ជាមួយភាពជាដៃគូពាណិជ្ជកម្ម បើទោះបីជាវាមានលក្ខណៈទូលំទូលាយជាងក៏ដោយ៖

- ការវិភាគស្ថានភាពខ្សែសង្វាក់តម្លៃ និងការវាយតម្លៃសក្តានុពលនៃបច្ចេកវិទ្យាជាក់លាក់មួយ (ឬកញ្ចប់បច្ចេកវិទ្យា) ដើម្បីដោះស្រាយឧបសគ្គខ្សែសង្វាក់តម្លៃ
- ការរៀបចំគម្រោងនៃសកម្មភាពនិងព្រឹត្តិការណ៍សំខាន់ៗសម្រាប់ការបង្កើនទំហំនៃគម្រោង

- ការរៀបចំសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងអង្គការកសិករ
- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាផ្លូវការរវាងដៃគូ (រួមទាំងអង្គការសង្គមស៊ីវិល អង្គការកសិករ ដែលជាប់ពាក់ព័ន្ធ) ការអនុវត្ត និងការត្រួតពិនិត្យ។

# 5. កត្តាជម្រុញនិងស្ថិរភាពនៃភាពជាដៃគូសាធារណៈ-ឯកជន

## 5.1 ដំណាក់កាលនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍និងការធ្វើពាណិជ្ជកម្មតាមខ្សែសង្វាក់តម្លៃ

គម្រោងធម្មតាមួយសម្រាប់ការផ្គត់ផ្គង់ទំនិញនិងសេវាកម្ម ដូចជាប្រភេទគ្រាប់ពូជថ្មី ការធ្វើតេស្តមន្ទីរពិសោធន៍ជាដើម ជាធម្មតាអាចត្រូវបែងចែកជា៤ដំណាក់កាល។ ដំណាក់កាលទាំងនេះមានដូចជា៖ ការរចនា ការកៀរគរធនធាន ការវិនិយោគ និងប្រតិបត្តិការ ពោលគឺការបង្កើតលំហូរនៃអត្ថប្រយោជន៍ឬសេវាកម្ម។ នៅក្នុងបរិបទនៃការស្រាវជ្រាវកសិកម្ម ការវិនិយោគគឺជាដំណាក់កាលស្រាវជ្រាវ ខណៈឯប្រតិបត្តិការគឺជាដំណាក់កាលនៃការអភិវឌ្ឍន៍និងការចែកចាយ។

តួនាទីរបស់វិស័យសាធារណៈនិងឯកជនអាចត្រូវបានចាត់តាំងតាមវិធីផ្សេងៗគ្នា។ ការស្រាវជ្រាវកសិកម្មសាធារណៈបែបប្រពៃណីគឺមានលក្ខណៈសាធារណៈសុទ្ធសាធ៖ ឧទាហរណ៍ទីភ្នាក់ងារ (ដែលមកពីក្រសួងកសិកម្ម) ផ្តល់ការស្រាវជ្រាវដល់សាកលវិទ្យាល័យដែលគ្រប់គ្រងដោយរដ្ឋ។ បច្ចេកវិទ្យាថ្មីនេះអាចត្រូវបានបញ្ជូនទៅប្រព័ន្ធពង្រីករបស់រដ្ឋាភិបាលដើម្បីផ្សព្វផ្សាយដល់កសិករ។ ចំណុចសំខាន់មួយទៀតគឺការអនុវត្តដែលមានភាពឯកជនសុទ្ធសាធ ដូចជានៅពេលដែលនាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍របស់ក្រុមហ៊ុនបង្កើតកម្មវិធីបច្ចេកវិទ្យាជីវបច្ចេកវិទ្យាថ្មី។

ភាពជាដៃគូសាធារណៈនិងឯកជនពាក់ព័ន្ធនឹងការរៀបចំរវាងភាគីទាំងពីរនេះ។ ភាពជាដៃគូធនធានដូចដែលឈ្មោះបានបានបង្ហាញ គឺវាពាក់ព័ន្ធនឹងការរួមចំណែកផ្នែកហិរញ្ញវត្ថុនិងអ្វីផ្សេងៗទៀតពីអង្គភាពឯកជនដែលជាទូទៅគឺជាមូលនិធិសប្បុរសធម៌។ ភាពជាដៃគូកិច្ចសន្យាទាក់ទងនឹងការស្រាវជ្រាវដែលបានប្រគល់ឱ្យក្រុមហ៊ុនឯកជនមួយ។ ទន្ទឹមនឹងនេះការធ្វើពាណិជ្ជកម្មក៏ដូចជាភាពជាដៃគូខ្សែសង្វាក់តម្លៃពាក់ព័ន្ធនឹងការអភិវឌ្ឍន៍និងការចែកចាយដែលត្រូវបានចាត់ចែងដោយអង្គភាពឯកជនដូចជាក្រុមហ៊ុនអាជីវកម្ម កសិពាណិជ្ជកម្មនិង/ឬសហករណ៍កសិករ។

## 5.2. អ្នកបើកបរនៃភាពជាដៃគូជាមួយវិស័យឯកជន

ការផ្គត់ផ្គង់ដែលមានលក្ខណៈសាធារណៈសុទ្ធសាធ គឺមានគុណសម្បត្តិច្រើនជាងនៅពេលដែលផលប្រយោជន៍ទទួលបានពីការស្រាវជ្រាវមានការពិបាកឬមិនអាចធ្វើពាណិជ្ជកម្មបាន។ ឧទាហរណ៍គ្រាប់ពូជបង្កាត់ពូជដែលល្អប្រសើរឡើង។ ក្រុមហ៊ុនឯកជនប្រហែលជាមិនអាចទទួលបានប្រាក់ចំណេញពីបច្ចេកវិទ្យានោះទេ។ ហេតុដូច្នេះប្រសិនបើគ្រាប់ពូជត្រូវបានបង្កើតឡើង ការស្រាវជ្រាវអាចត្រូវបានធ្វើឡើងដោយវិទ្យាស្ថានស្រាវជ្រាវសាធារណៈដែលទទួលបានមូលនិធិដោយអ្នកបង់ពន្ធ ហើយនិងត្រូវរៀបចំដើម្បីផលិតទំនិញសាធារណៈ។

ម៉្យាងវិញទៀតដោយសារកាលៈទេសៈខុសប្លែកគ្នា ការវាយតម្លៃអត្ថប្រយោជន៍ (value-for-money )អាចទទួលបានលទ្ធផលខ្ពស់ដោយការចូលរួមពីវិស័យឯកជន។ កត្តាជំរុញតម្លៃនៃអត្ថប្រយោជន៍

ទាំងនេះបង្ហាញពីអត្ថប្រយោជន៍កាន់តែច្រើនសម្រាប់ការរៀបចំដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍន៍បច្ចេកវិទ្យាដោយវិស័យឯកជន។ កត្តាជំរុញទាំងនេះត្រូវមានដូចជាចំណុចខាងក្រោមៈ

1. វិស័យឯកជនមានសមត្ថភាពទទួលបានប្រាក់ចំណេញពីផលិតផលបច្ចេកវិទ្យា។
2. វិស័យឯកជនមានសមត្ថភាពអភិវឌ្ឍន៍បច្ចេកវិទ្យាដែលមានសក្តានុពលទីផ្សារខ្លាំង។
3. វិស័យឯកជននិងសាធារណៈមានសមត្ថភាពជំនាញដោយសារទំហំសេដ្ឋកិច្ចនិងការវិនិយោគកន្លងមក។
4. វិស័យឯកជនអាចមានលទ្ធភាពពន្លឿនដំណើរការបច្ចេកវិទ្យាថ្មីៗ។
5. ការចូលរួមពីវិស័យឯកជនអាចនាំឱ្យមានការកែលម្អគុណភាពនៃដំណោះស្រាយបច្ចេកវិទ្យាដែលបានផ្តល់ជូន។
6. ការចូលរួមរបស់វិស័យឯកជនអនុញ្ញាតឱ្យមានការចែករំលែកហានិភ័យ ការជំរុញការលើកទឹកចិត្ត និងការបំពេញបន្ថែមនៅក្នុងដំណាក់កាលនិមួយៗ។
7. ភាពជាដៃគូអាចធ្វើទៅបាននៅពេលដែលលទ្ធផលអាចវាស់វែងបានដោយផ្អែកលើសូចនាករលទ្ធផលដែលបានកំណត់ទុកជាមុន។
8. សប្បុរសធម៌ឯកជន និងអាជីវកម្មរួមបញ្ចូលគ្នាអាចកៀរគរធនធានបន្ថែមសម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម និងព្រៃឈើ ដែលវិស័យសាធារណៈតែម្នាក់ឯងមិនអាចធ្វើបាន។

ការស្រាវជ្រាវប្រភេទខ្លះអាចត្រូវបានរៀបចំឡើងដោយល្អបំផុតបើសិនជាត្រូវបានរៀបចំដោយឯកជនសុទ្ធសាធ។ ឧទាហរណ៍ ថាផលិតផលស្រាវជ្រាវអាចមានប៉ាតង់ ហើយផលិតកម្មមានការកំណត់ចំពោះអ្នកកាន់ប៉ាតង់ ឧទាហរណ៍ដូចជាការបង្កើតពូជកូនកាត់ថ្មីដែលលក្ខណៈរបស់វាជាតម្រូវការក្នុងទីផ្សារ (កត្តាជំរុញទី ១ និងទី ២)។ អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃការដាំគ្រាប់ពូជនេះ អាចត្រូវបានផ្តល់ដោយក្រុមហ៊ុនគ្រាប់ពូជ។ កម្លាំងជំរុញពាណិជ្ជកម្មអាចគ្រប់គ្រាន់ សម្រាប់ការជម្រុញដល់ការរចនាហិរញ្ញវត្ថុ សកម្មភាពស្រាវជ្រាវ និងការផ្សព្វផ្សាយ បច្ចេកវិទ្យាថ្មី។ លើសពីនេះទៅទៀតក្រុមហ៊ុនគ្រាប់ពូជអាចមានប្រវត្តិអតីតកាលក្នុងការវិនិយោគលើឧបករណ៍មន្ទីរពិសោធន៍ និងអ្នកវិទ្យាសាស្ត្រដោយបានដឹងពីសេដ្ឋកិច្ចខ្នាត និងសមត្ថភាពឯកទេស (កត្តាជំរុញទី៣)។ វិស័យសាធារណៈអាចនៅតែទទូចចង់ធ្វើការស្រាវជ្រាវដោយខ្លួនឯង ប៉ុន្តែការចំណាយច្រើន ហើយវាជារឿងដែលមិនចាំបាច់ក្នុងការធ្វើការស្រាវជ្រាវស្ទួនលើការស្រាវជ្រាវរបស់ផ្នែកឯកជន។

ការចូលរួមរបស់វិស័យឯកជនក៏អាចធ្វើឱ្យមានការលើកទឹកចិត្តដល់ការស្រាវជ្រាវផងដែរ ព្រោះបើមិនមានការចូលរួមរបស់ពួកគេទេ ការលើកទឹកចិត្តនេះនឹងត្រូវបានរារាំង នៅក្នុងការស្រាវជ្រាវវិស័យសាធារណៈ។ ការស្រាវជ្រាវរបស់វិស័យសាធារណៈ អាចត្រូវបានកំណត់ដោយភាពយឺតយ៉ាវនៃការស្រាវជ្រាវរយៈពេលយូរនិងមានការចំណាយខ្ពស់។ ផលិតផលបច្ចេកវិទ្យាខ្លះក៏អាចមិនមានប្រសិទ្ធភាពឬ មិនមានភាព ងាយស្រួលប្រើផងដែរ។ ផ្ទុយទៅវិញវិស័យឯកជនស្វែងរកភាពការស្រាវជ្រាវ ដែលអាចធ្វើទៅបានក្នុងរយៈពេលខ្លីបំផុត ហើយផលិតផលគឺជាផលិតផល ដែលមាន គុណភាពនិងសក្តានុពលទាក់ទាញដល់អ្នកប្រើប្រាស់ (កត្តាជំរុញទី ៤ និងទី ៥) ។

ចំពោះការវិនិយោគខ្នាតធំៗ ហានិភ័យប្រឈមនឹងការលំបាកដែលបានរៀបរាប់ ខាងលើនៅគ្រប់ដំណាក់កាលនៃគម្រោងស្រាវជ្រាវមានកម្រិតកាន់តែខ្ពស់។ ហានិភ័យអាចពាក់ព័ន្ធនឹងការរចនាមិនត្រឹមត្រូវ ការខ្វះគោលបំណងវិនិយោគ ការបរាជ័យក្នុងការសំរេចគោលបំណងស្រាវជ្រាវ (ឬការពន្យារពេលយូរក្នុងការ សម្រេចបានជោគជ័យក្នុងការស្រាវជ្រាវ) និងការឈានដល់គោលដៅនៃការ ស្រាវជ្រាវ។ តាមរយៈការរៀបចំរចនាសម្ព័ន្ធបច្ចេកវិទ្យា គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ហានិភ័យអាច ត្រូវបានកាត់បន្ថយតាមរយៈការបែងចែកហានិភ័យដល់ដៃគូដែលអាចគ្រប់គ្រងវាបានល្អប្រសើរជាង ក៏ដូចជាយល់ពីការបំពេញបន្ថែមនៅគ្រប់ដំណាក់កាល (កត្តាជំរុញទី ៦) ។ ការកាត់បន្ថយហានិភ័យនិងការលើកទឹកចិត្តអាចមានរចនាសម្ព័ន្ធ ល្អប្រសើរប្រសិនបើការអនុវត្តនិងការផ្តល់ជូនមានភាពងាយស្រួលក្នុងការវាស់ស្ទង់ (កត្តាជំរុញទី ៧) ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលវិស័យឯកជនស្ថិតនៅឆ្ងាយពីដំណាក់កាលនៃការអភិវឌ្ឍន៍ដែលមានភាពចាស់ទុំ វិស័យសាធារណៈអាចជាដៃគូជាមួយនឹងការវិនិយោគធំៗក្នុងការច្នៃប្រឌិតនិងបច្ចេកវិទ្យាកសិកម្ម។ ភាពជាដៃគូកិច្ចសន្យាអាចផ្តល់ឱ្យវិស័យសាធារណៈជាអ្នកអនុវត្តការស្រាវជ្រាវខណៈការរចនាហិរញ្ញវត្ថុនិងពាណិជ្ជកម្មអាចត្រូវបានអនុវត្តដោយក្រុមហ៊ុនឯកជន។
ចំណុចចុងបញ្ចប់ ការវិនិយោគដើម្បីផលប្រយោជន៍សាធារណៈមិនចាំបាច់ទាល់តែធ្វើឡើងដោយរដ្ឋាភិបាលផ្តាច់មុខនោះទេ។ សប្បុរសជនឯកជនអាចត្រូវបានរៀបចំ ឡើង និងផ្តល់អំណោយក្នុងការផ្គត់ផ្គង់ទំនិញសាធារណៈ (កត្តាជំរុញទី ៨) ។
វិនិយោគិនដែលមានការព្រួយបារម្ភពីសង្គម អាចមានការចាប់អារម្មណ៍លើការធ្វើអាជីវកម្មបច្ចេកវិទ្យាដែលបង្កើនទំហំនិងពង្រីកផលប៉ះពាល់ល្អដល់កសិករក្រីក្រ និងសហគ្រាសធុនតូចនិងមធ្យមដែលមិនមានធនធាន។ អង្គការកសិករអាចជួយសម្រួលដល់ការតភ្ជាប់អ្នកដាំដុះខ្នាតតូចជាមួយវិនិយោគិន ខណៈអង្គការសង្គមស៊ីវិលអាចគាំទ្រដល់ការបង្កើតអង្គការកសិករទាំងនេះឬ ជួយក្នុងការផ្សាភ្ជាប់អង្គការកសិករជាមួយវិនិយោគិន។

# 6. ផែនការសកម្មភាពដើម្បីលើកកម្ពស់ការអនុវត្តគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)

## 6.1 ការយល់ដឹងអំពី ភាពជាដៃគូសាធារណៈនិងឯកជន (PPP) និងការកំណត់អត្ត សញ្ញាណឱកាស

ដោយសារនៅក្នុងបរិបទសមាគមអាស៊ានបច្ចុប្បន្ន ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ការបង្កើត ការយល់ដឹងអំពីអត្ថប្រយោជន៍នៃភាពជាដៃគូសាធារណៈនិងឯកជន សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា(ដែលអាចរួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធផងដែរ)  ការទទួលយក និងការផ្សព្វផ្សាយជាពិសេសនៅក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) គឺជាតម្រូវការចាំបាច់។ ដើម្បីលើកកម្ពស់សក្តានុពលរបស់ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ការផ្តល់ព័ត៌មានដែលពាក់ព័ន្ធទៅកាន់ភាគីដែលមានចំណាប់អារម្មណ៍គឺមានសារៈសំខាន់ជាខ្លាំង។ អ្វីដែលត្រូវធ្វើទាំងនេះរួមបញ្ចូលទាំងការសម្លឹងមើលគម្រោង ដែលមានស្រាប់នៅក្នុងតំបន់ និងការអនុវត្តល្អបំផុតរបស់ គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)ក្នុងតំបន់ផ្សេងទៀត ក៏ដូចជាការកំណត់ឱកាស និងភាគីដែលចាប់អារម្មណ៍ក្នុងការ អភិវឌ្ឍន៍

ផលប័ត្រនៃគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យានៅក្នុងតំបន់ និងក្នុងរដ្ឋដែលជា សមាជិក។

ការលើកកម្ពស់ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) នៅកម្រិតតំបន់ កម្រិតឆ្លងប្រទេស ឬរដ្ឋដែលជាសមាជិកនៅក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ទាមទារឱ្យរដ្ឋដែលជាសមាជិកបន្តដំណើរការយ៉ាងសកម្មជាមួយដំណើរការអនុវត្តរបស់ភាគីពាក់ព័ន្ធ និងការសន្ទនាអំពី ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដើម្បីកំណត់អត្តសញ្ញាណឱកាស និងជួយសម្រួលនិងពិនិត្យមើលលើការអនុវត្ត។
រដ្ឋដែលជាសមាជិកត្រូវតែដឹងអំពីអត្ថប្រយោជន៍នៃការធ្វើកំណែទម្រង់វិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) និងតួនាទីរបស់វាក្នុងការអភិវឌ្ឍន៍និងគាំទ្រគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)។ លើសពីនេះរដ្ឋដែលជាសមាជិកគួរតែទទួលស្គាល់ពីតម្រូវការសម្រាប់ការប្តេជ្ញាចិត្តផ្នែកនយោបាយដើម្បីឆ្ពោះទៅរកការលើកកម្ពស់គ្រោងការណ៍ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) នៅក្នុងវិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ដែលឆ្ពោះទៅរកការអភិវឌ្ឍន៍ បច្ចេកវិទ្យា។

ព័ត៌មានដែលបានបង្កើតឡើងនឹងត្រូវបានផ្សព្វផ្សាយនៅក្នុងយុទ្ធនាការព័ត៌មាននិងការអប់រំ។ យុទ្ធនាការនេះនឹងផ្តោតសំខាន់ទៅលើគំនិតផ្តួចផ្តើមជាទូទៅរបស់គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) នៅក្នុងរដ្ឋដែលជាសមាជិក ហើយយុទ្ធនាការនេះនឹងបង្កើនការយល់ដឹង អំពីផ្នែកជាក់លាក់នៃភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់បច្ចេកវិទ្យាកសិកម្ម (និងមិនត្រឹមតែលើហេដ្ឋារចនាសម្ព័ន្ធទេ)។ យុទ្ធនាការនេះក៏នឹងត្រូវបានរៀបចំឡើងនៅលើគំនិតផ្តួចផ្តើមវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកសិកម្មជាទូទៅនៅក្នុង និងក្នុងចំណោមរដ្ឋដែលជាសមាជិកដោយបង្កើនការយល់ដឹងអំពីតួនាទីនៃភាពជាដៃគូនិងកិច្ចសហការ។ សម្រាប់គម្រោងចុងក្រោយ យុទ្ធនាការនេះ គួរតែលើកស្ទួយបណ្តាញវិទ្យាសាស្ត្រនិង បច្ចេកវិទ្យាកសិកម្មជាតិនិងអន្តរជាតិ។

**បណ្តាញវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាទាក់ទងនឹងចំណីអាហារ កសិកម្ម ព្រៃឈើក្នុងតំបន់អាស៊ាន**

*វិទ្យាស្ថានស្រាវជ្រាវកសិកម្មអាស៊ីប៉ាស៊ីហ្វិក (APAARI)*

*ការផ្លាស់ប្តូរដោយលើកកម្ពស់ការអប់រំគុណភាពការស្រាវជ្រាវនិងការបណ្តុះបណ្តាលនៅអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ (EXPERTS)*

*អាស៊ីៈ វិទ្យាសាស្ត្រជីវិតម្ហូបអាហារកសិកម្មជីវវិទ្យាសេដ្ឋកិច្ចបច្ចេកវិទ្យា (អាល់ហ្វាបេត) (ALFABET)*

*បណ្តាញវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអាស៊ាន (ASTNET)*

*កិច្ចសហប្រតិបត្តិការអាស៊ាន - សហភាពអឺរ៉ុបផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍ (ASEAN-EU-NET)*

*បណ្តាញស្រាវជ្រាវអនុតំបន់មេគង្គ (GMSARN)*

*បណ្តាញកសិកម្មអភិរក្សនៅអាស៊ីអាគ្នេយ៍ (CANSEA)*

*បណ្តាញព្រៃឈើសង្គមអាស៊ាន (ASFN)*

*បណ្តាញដែលពាក់ព័ន្ធផ្សេងទៀតគឺៈ*
*សម្ព័ន្ធសាកលវិទ្យាល័យអាស៊ីអាគ្នេយ៍សម្រាប់ការអប់រំជាន់ខ្ពស់ផ្នែកកសិកម្មនិងធនធានធម្មជាតិ (សាកលវិទ្យាល័យសម្ព័ន្ធ) និងក្រុមស្រាវជ្រាវដែលរៀបចំឡើងដោយក្រុមពិគ្រោះយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ (CGIAR)*

## 6.2ការកសាងសមត្ថភាពនិងឧបករណ៍ត្រៀមខ្លួនសម្រាប់គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)

ភ្ជាប់ទៅចំនុចខាងលើ គឺជាឧបករណ៍វាយតម្លៃការត្រៀមខ្លួនដើម្បីកំណត់ពីចន្លោះប្រហោងនិងតម្រូវការកសាងសមត្ថភាពរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ និងស្ថាប័ននិងអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ ដទៃទៀត។ ឧបករណ៍វាយតម្លៃការត្រៀមខ្លួនរបស់ គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) មួយចំនួនដែលកំពុងត្រូវបាន ប្រើឬស្នើសុំមានដូចជា៖

- ឧបករណ៍ថតកាំរស្មីពីអង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (EIU)
- ឧបករណ៍វាយតម្លៃតម្រូវការរហ័សនៃកន្លែងប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធសាធារណៈ-ឯកជន
- ឧបករណ៍វាយតម្លៃដែលបង្កើតឡើងដោយគណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP)
- សំណុំនៃឧបករណ៍ពីធនាគារពិភពលោកដែលមានដូចជា៖ ឧបករណ៍ស្ថានភាពរៀបចំគម្រោងPPP គំរូវាយតម្លៃហានិភ័យសារពើពន្ធលើគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) និងឧបករណ៍ធ្វើចំណាត់ថ្នាក់លើគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)

ជាគំរូមនៅក្នុងឧបករណ៍វាយតម្លៃទាំងនេះគឺ៖

- ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ - ភាពច្បាស់លាស់ ការគាំទ្រ ដំណើរការល្អ
- ក្របខ័ណ្ឌស្ថាប័ន - គុណភាពនៃទីភ្នាក់ងារ/អង្គភាព ដែលអនុវត្តគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP)
- ការអភិវឌ្ឍនិងការអនុវត្ត - តម្លាភាពនិងយុត្តិធម៌ក្នុងការផ្តល់រង្វាន់ដល់គម្រោង ការបញ្ជាក់ និងការចរចាកិច្ចសន្យា

អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (EIU) និងធនាគារពិភពលោកវាយតម្លៃលើធនធាន ហិរញ្ញវត្ថុ ពោលគឺផ្តល់ការគាំទ្រថវិកាដល់ការអនុវត្តគម្រោង គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ក្របខ័ណ្ឌហិរញ្ញវត្ថុ សាធារណៈ ជម្រៅនៃទីផ្សារហិរញ្ញវត្ថុឯកជន។ ទន្ទឹមនឹងនេះ គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) និង អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (EIU) រួមបញ្ចូលបរិបទម៉ាក្រូសេដ្ឋកិច្ច និងបរិយាកាសវិនិយោគនៅក្នុងឧបករណ៍វាយតម្លៃរបស់ពួកគេផងដែរ។

ជាទូទៅឧបករណ៍វាយតម្លៃការត្រៀមខ្លួនត្រូវបានគេជឿថាបានបង្កើតឡើងដោយផ្តោតលើហេដ្ឋារចនាសម្ព័ន្ធរបស់ គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ។ វាមានតំរូវការដើម្បីបង្កើតឧបករណ៍ត្រៀមខ្លួនសម្រាប់ គម្រោងភាពជាដៃគូ សាធារណៈនិងឯកជន (PPP) ជាពិសេសសម្រាប់ការអភិវឌ្ឍន៍ បច្ចេកវិទ្យានៅក្នុងវិ ស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ។ ឧបករណ៍ទាំងនេះត្រូវតែជាកំណែប្រែនៃឧបករណ៍ដែលមានស្រាប់ដើម្បីធ្វើឱ្យពួកវាកាន់តែមានភាពពាក់ព័ន្ធនឹងការអភិវឌ្ឍន៍បច្ចេកវិទ្យានៅ ក្នុងវិស័យ ស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ។ ឧបករណ៍ទាំងនេះមានដូចជា៖

- បរិយាកាសនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍- ការចំណាយលើកសិកម្មសាធារណៈលើការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម ការស្រាវជ្រាវនិងការអភិវឌ្ឍន៍លើការវិនិយោគវិស័យកសិកម្មឯកជន លទ្ធភាពទទួលបាននូវចំណេះដឹងនិងបច្ចេកវិទ្យាថ្មីៗមួយនៃអត្រាកំណើននៃវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) និងឧស្សាហកម្មកែច្នៃកសិផល អត្រាកំណើននៃការនាំចេញកសិផល
- បរិយាកាសវិនិយោគសម្រាប់ការធ្វើពាណិជ្ជកម្មវិសាលភាពនៃការរៀបចំផ្លូវការរបស់កសិករ ការតំរង់ទិសពាណិជ្ជកម្មរបស់កសិករនិងអង្គការកសិករ

ឆន្ទៈនៃការធ្វើកសិឧស្សាហកម្មដើម្បីរកប្រភពវត្ថុធាតុដើមក្នុងស្រុកនិងសហការជាមួយអង្គការកសិករ។

- ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ- ច្បាប់តម្លាភាពស្តីពីកម្មសិទ្ធិបញ្ញា ការផ្តល់ អាជ្ញាប័ណ្ណបច្ចេកវិទ្យាដែលមានកម្មសិទ្ធិ និងបទបញ្ញាបរិស្ថាននិងសុខភាពសម្រាប់បច្ចេកវិទ្យាកសិកម្ម វត្តមាននៃក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដោយ យុត្តិធម៌ តម្លាភាព និងមុខងារសម្រាប់ការធ្វើកសិកម្មតាមកិច្ចសន្យា និងការរៀបចំដែលពាក់ព័ន្ធ(ឧទាហរណ៍ការបណ្តាក់ទុនកសិពាណិជ្ជកម្មរួមគ្នា)

ក្របខ័ណ្ឌស្ថាប័ន- ការយល់ដឹងអំពីប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ ការធ្វើកសិ ពាណិជ្ជកម្ម និងអង្គការកសិករទាក់ទងនឹងការរៀបចំនិងសក្តានុពលរបស់គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) សមត្ថភាពរបស់ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិក្នុងការរៀបចំរចនាសម្ព័ន្ធ កិច្ចសន្យាគម្រោងភាពជាដៃគូសាធារណៈនិងឯកជន ការតាមដាននិងវាយតម្លៃសូចនាករនៃការអនុវត្តគម្រោងភាពជាដៃគូសាធារណៈនិងឯកជន។

## 6.3ការសន្ទនាឯកជននិងសាធារណៈនិងវេទិកាភាពជាដៃគូសាធារណៈនិងឯកជន (PPP)

ដើម្បីលើកកម្ពស់ គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យា ការទទួលយកនិងការចែកចាយនៅក្នុងវិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ការបង្កើនកិច្ចសន្ទនាសាធារណៈនិងឯកជនគឺជាតម្រូវការសំខាន់មួយ។ យុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់ការសន្ទនាសាធារណៈនិងឯកជនដើម្បីលើកកម្ពស់ភាពជាដៃគូសាធារណៈនិងឯកជន (PPP) អាចត្រូវបានបង្កើតឡើងទាំងក្នុងតំបន់និងកម្រិតរដ្ឋដែលជាសមាជិក។ ការសន្ទនានេះអាចរួមបញ្ចូលដូចជាវេទិកាពិភាក្សាដើម្បីផ្តល់“លំហ” សម្រាប់ជាឱកាសបង្កើតបណ្តាញសម្រាប់អ្នកពាក់ព័ន្ធដែលមានការបែងចែក ហើយពួកគេទាំងនោះគឺជាអ្នកដែលមានទ្រព្យសម្បត្តិ ចំណេះដឹង និងបទពិសោធន៍ផ្សេងៗគ្នាដែលអាចប្រមូលផ្តុំគ្នាក្នុងការកំណត់ឱកាសរបស់ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ។ វេទិកានេះមិនត្រឹមតែរួមបញ្ចូលទាំងវិស័យសាធារណៈ (សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ និងការត្រួតពិនិត្យ) និងដៃគូឯកជន (ការស្រាវជ្រាវ អ្នកផ្គត់ផ្គង់ និងចែកចាយបច្ចេកវិទ្យា) ប៉ុន្តែថែមទាំងអង្គការសង្គមស៊ីវិល (ការកៀងគរសហគមន៍) ការស្រាវជ្រាវនិងសហគមន៍វិទ្យាសាស្ត្រ (ស្រាវជ្រាវ) និង ដៃគូអភិវឌ្ឍន៍ (ធនធាននិងការសម្របសម្រួលដំណើរការ) ។ ហេតុនេះការទំនាក់ទំនងគួរតែផ្តោតលើអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់នេះ។ វេទិកាបែបនេះក៏អាចបម្រើដល់ការផ្លាស់ប្តូរព័ត៌មាននិងយន្តការពិនិត្យឡើងវិញនិងការត្រួតពិនិត្យការអនុវត្តគម្រោង ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ផងដែរ។

សៀវភៅណែនាំរបស់ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា បានណែនាំឱ្យមានការបង្កើតវេទិកា ភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដើម្បីធ្វើឱ្យមាននូវគោលការណ៍ណែនាំនៃភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដែលច្បាស់លាស់និងអាចដំណើរការបាន ដើម្បីបង្កើនការផ្សព្វផ្សាយនិងបង្កើតការយល់ឃើញស្មើៗគ្នានៅក្នុងរដ្ឋជាសមាជិក។ វេទិកាដែលបានស្នើនេះក៏នឹងគាំទ្រដល់ការបញ្ចូលមតិត្រឡប់តតឈប៉ឈរពីភាគីពាក់ព័ន្ធផងដែរ។ ទំនាក់ទំនងគំនិត និងវិធីសាស្ត្រជាក់ស្តែងរបស់ PPP ផ្តល់ការផ្លាស់ប្តូរចំណេះដឹង និងចែករំលែកបទពិសោធន៍។

ផ្អែកលើសំណូមពរនេះ ក្របខ័ណ្ឌនេះស្នើឱ្យមានវេទិកាអាស៊ាន/កិច្ចសន្ទនាស្តីពីការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម និងព្រៃឈើ (ដែលបានហៅថា វេទិកា)។ វេទិកានេះមានការចូលរួមពីអង្គការ ប្រព័ន្ធស្រាវជ្រាវកសិកម្មជាតិ (រួមទាំងការផ្សព្វផ្សាយផ្អែកកសិកម្មសាធារណៈ) អ្នកតំណាងវិស័យកសិ - ឧស្សាហកម្ម អង្គការសង្គមស៊ីវិល អង្គការដៃគូនិងដៃគូ និងដៃគូអភិវឌ្ឍន៍។

ការវិភាគអ្នកពាក់ព័ន្ធនឹងត្រូវធ្វើឡើងដើម្បីធានាថាទស្សនិកជនគោលដៅត្រូវបានអញ្ជើញឱ្យចូលរួមវេទិកានេះ។

វេទិកាដែលបានស្នើឡើងនៅ ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) នឹងធ្វើជាកន្លែងសម្រាប់ការផ្លាស់ប្តូរព័ត៌មាន ការផ្សព្វផ្សាយការអនុលោមភាពដោយស្ម័គ្រចិត្ត ក៏ដូចជាការរាយការណ៍/ការត្រួតពិនិត្យលើគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) នៅអាស៊ាន។ ការរៀបចំវេទិកានេះអាចធ្វើទៅបានដោយស្ថាប័នអាស៊ានលើ វិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ដែលបានចាត់ចែងដល់វេទិការពិភាក្សាពីការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ចំណីអាហារ កសិកម្ម និងព្រៃឈើដែលមានដូចជា ក្រុមការងារបច្ចេកទេសអាស៊ានស្រាវជ្រាវនិងអភិវឌ្ឍន៍ស្តីពីវិស័យកសិកម្ម (ATWGARD) ក្រុមការងារតំបន់អាស៊ានស្តីពីដំណាំ (ASWGC) ក្រុមការងារតំបន់អាស៊ានស្តីពីបសុសត្វ (ASWGL) ក្រុមការងារតំបន់អាស៊ានស្តីពីជលផល (ASWGFi) និង មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ (ASOF)។ ចំនុចមួយចំនួនរបស់ភាពជាដៃគូសាធារណៈនិងឯកជន (PPP) នៅក្នុងរបៀបវារៈនៃវេទិកាអាចមានដូចជា៖ ការលើកកម្ពស់ការយល់ដឹង ការស្រង់ទិន្នន័យប្រទេសដោយមើលលើការត្រៀមខ្លួនរបស់គេលើគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ការចែករំលែកបទពិសោធន៍ និងមេរៀនដែលទទួលបាន និងការកំណត់អត្តសញ្ញាណឱកាស។ ក្រៅពីឯកសារនៃកិច្ចប្រជុំធម្មតា វេទិកាត្រូវភ្ជាប់មកជាមួយនូវគេហទំព័រ និងគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់ការទំនាក់ទំនង ការតស៊ូមតិ និងការតាមដាន គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ។ ដោយមើលលើផែនការយុទ្ធសាស្រ្តបច្ចុប្បន្ននៃសកម្មភាពសន្តិសុខស្បៀង (២០១៥-២០២០) គេហទំព័រអាចបម្រើជាវិបផតថលសម្រាប់បច្ចេកវិទ្យាដែលមានសក្តានុពលពាណិជ្ជកម្មខ្ពស់ដើម្បីជូនដំណឹងដល់វិនិយោគិន និងដៃគូអង្គការកសិករដែលមាន សក្តានុពល។ សម្រាប់ការផ្តល់មូលនិធិ ស្ថាប័នអាស៊ានលើវិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) អាចស្នើសុំធនធានពីរដ្ឋដែលជាសមាជិក (AMS) អង្គការរីកចម្រើនអាស៊ី (GrowAsia) មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការសិក្សាជាន់ខ្ពស់ការសិក្សានិងស្រាវជ្រាវកសិកម្ម (SEARCA) ដៃគូសន្ទនា និងទីភ្នាក់ងារដែលពាក់ព័ន្ធផ្សេងៗ។

## 7. ការអនុវត្តនិងការគ្រប់គ្រង

នៅសមាគមអាស៊ាន ក្រុមការងារបច្ចេកទេសអាស៊ានស្រាវជ្រាវនិងអភិវឌ្ឍន៍ស្តីពីវិស័យកសិកម្ម (ATWGARD), ក្រុមការងារតំបន់អាស៊ានស្តីពីដំណាំ (ASWGC), ក្រុមការងារតំបន់អាស៊ានស្តីពីបសុសត្វ (ASWGL) និង ក្រុមការងារតំបន់អាស៊ានស្តីពីជលផល (ASWGFi) ព្រមទាំង មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ (ASOF) និងស្ថាប័នអាស៊ានដទៃទៀតដែលស្ថិតនៅក្រោមវិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) ទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍និងការអនុវត្តក្របខ័ណ្ឌ រួមជាមួយស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិក្រោមការណែនាំរបស់កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់នៃក្រសួងកសិកម្មនិងរុក្ខាប្រមាញ់អាស៊ាន (SOM-AMAF)។ រដ្ឋជាសមាជិកនឹងទទួលខុសត្រូវចំពោះការអនុម័ត ការរចនា និង

ដំណើរការអនុវត្ត គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ដោយស្របតាមគោលនយោបាយនិងក្របខ័ណ្ឌជាតិនិងតំបន់។

ប្រហាក់ប្រហែលនឹងគោលការណ៍សមាគមអាស៊ានសម្រាប់ក្របខ័ណ្ឌភាពជាដៃគូសាធារណៈនិងឯកជន (PPP) ផងដែរ គឺក្របខ័ណ្ឌគម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) ត្រូវបានបង្កើតឡើងជាមគ្គុទ្ទេសក៍សម្រាប់រដ្ឋជាសមាជិកដោយផ្តល់នូវអនុសាសន៍ដែលមិនមែនជាកាតព្វកិច្ច ប៉ុន្តែមានប្រយោជន៍ចំពោះការពង្រឹងក្របខ័ណ្ឌ ភាពជាដៃគូសាធារណៈនិងឯកជន (PPP) សម្រាប់ ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) នៅក្នុងរដ្ឋសមាជិកនីមួយៗ។ វេទិកាដែលបានស្នើឡើងនៅ ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF)

នឹងធ្វើជាកន្លែងសម្រាប់ការផ្សព្វផ្សាយ ការអនុលោមភាពដោយការស្ម័គ្រចិត្ត និងការធ្វើរបាយការណ៍/ការត្រួតពិនិត្យលើ ភាពជាដៃគូសាធារណៈនិងឯកជន សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) នៅតំបន់អាស៊ាន។
ដូច្នេះវេទិកានេះនឹងមិនចម្លងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកសិកម្មដែលមានស្រាប់នៅក្នុងអាស៊ានរួមទាំងស្ថាប័នសិក្សាផងដែរ។
អ្នកចូលរួមក្នុងបណ្តាញទាំងនេះអាចត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវេទិកានេះផងដែរ។

ក្រុមការងារបច្ចេកទេសអាស៊ានស្រាវជ្រាវនិង
អភិវឌ្ឍន៍ស្តីពីវិស័យកសិកម្ម (ATWGARD) ដោយមានការគាំទ្រពីស្ថាប័នអាស៊ាន ក្នុងវិស័យ ស្បៀងអាហារ កសិកម្ម និងព្រៃឈើ (FAF) នឹងបង្កើតផែនការសន្ទនា គម្រោងភាពជាដៃគូសាធារណៈនិងឯកជន (PPP) ២០១៨-២០២៥ ដែលវេទិកានេះនឹងក្លាយជាសកម្មភាពស្នូលនៃគម្រោង។ ផែនការសន្ទនា ភាពជាដៃគូសាធារណៈនិងឯកជន (PPP) នឹងបង្ហាញពីគោលដៅ គោលបំណង និងលទ្ធផលដែលបានគ្រោងទុកនៃការសន្ទនាលើភាពជាដៃគូសាធារណៈនិងឯកជន (PPP)ដើម្បីទទួលបានការអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់វិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (TDFAF) ស្នើបង្កើតកម្មវិធីសកម្មភាពនិងរបៀបវារៈសម្រាប់វេទិកា និងកំណត់ប្រភពនៃការគាំទ្រផ្នែកហិរញ្ញវត្ថុ។